# ធម្មប្រទីបសម្រាប់កុមារ



រៀបចំដោយអង្គការជំនួយព្រះធម៌កម្ពុជាសហការជាមួយ
អង្គការកម្មវិធីអភិវឌ្ឍន៍ធនធានយុវជន

*Prepared by Dhamma Aid Cambodia in Cooperation with the Youth Resource Development Program*

ចែកជូនដោយឥតគិតថ្លៃ

For free distribution

# បរិណ្ណកសង្ខេប

## គណៈកម្មការនាយក

លោក ផាន់ ពុធ　　　　　　　　　　លោក ជីង សុផុន

## គណៈកម្មការរៀបរៀង

លោក ប្រាក់ គង់　　　　　　　　　　លោក មាស សំបូរ

## គណៈកម្មការពិនិត្យ និងកែសម្រួល

| | |
|---|---|
| ១. ជា សារឿន | ៦. ង៉ែត ស័ញ្ញ |
| ២. នង ធារី | ៧. អ៊ុក សែម |
| ៣. ទូន គិមហ៊ាន | ៨. យឹម យុន |
| ៤. ហែម ថុល | ៩. សុខ សុង |
| ៥. ខាន់ សៀន | ១០. ជាង សុខា |

## អ្នកវាយអង្គុយលីលេខ

កញ្ញា ហុក ម៉ារីលីន　　　　　　　　　　កញ្ញា អ៊ិន ហេមរី

ព.ស.២៥២៤　　　　　　គ.ស.១៩៨១

# បុព្វកថា

សៀវភៅអធិប្បាយប្រជុំកងធម៌សង្ខេបនេះ រៀបរៀងឡើងដោយគណៈកម្មការនិពន្ធ (SBT) ។ ក្រោមការឧបត្ថម្ភរបស់អង្គការ J.S.R.C ក្នុងគោលបំណង ៣យ៉ាងគឺ ៖

១. ដើម្បីទុកជាជំនួយដល់លោកគ្រូដែលបង្រៀនខាងព្រះពុទ្ធសាសនា ងាយមិនពិបាក ស្រាវជ្រាវរកកម្រងធម៌មកបង្រៀន។

២.ដើម្បីជាការងាយស្រួលដល់សិក្ខានុសិស្ស ដែលសិក្សាខាងធម្មវិន័យ ងាយយល់ ទន្ទេញ និងអាន។

៣. ទុកជាសម្បត្តិនៃព្រះពុទ្ធសាសនា សម្រាប់ជនានុជន ដែលត្រូវការសិក្សាកងធម៌ជំពូកនេះ។

ដោយការដកស្រង់នឹងបំប្រួញអត្ថន័យក្នុងធម៌និមួយៗ យកតែគោលសំខាន់ៗខ្លះមកនិយាយនោះ ជាការពិបាកម្យ៉ាងដែលយើងខ្ញុំជឿជាក់ថា ប្រាកដជាមានការខ្វះចន្លោះដោយអចេតនាមិនខាន។

យើងខ្ញុំសូមសង្ឃឹមលើមនសិការ និងការរិះគន់អំពីសំណាក់ពុទ្ធបរិសទ័ និងអស់លោកអ្នកសិក្សាដោយសោមនស្សជាទីបំផុត ដើម្បីបានកែសម្រួលក្នុងការរៀបរៀងកម្រងធម៌ក្រោយៗ ទៀតឱ្យបានល្អប្រសើរឡើង។

គណៈកម្មការនិពន្ធ (SBT)

# អារម្ភកថា

បំណងយើងខ្ញុំ ដែលបានប្រឹងខំ ចាត់ចែងរៀបរៀង
បង្កើតជាក្បួន កងធម៌នេះឡើង ដើម្បីដំកើង
និស្ស័យកុមារ ។

ឱ្យដឹងយល់ជាក់ នៅហេតុគ្រោះថ្នាក់ ផ្លូវទុក្ខវេទនា
ដែលអាចឱ្យផល ដល់គ្រប់រូបា ជ្រើសរើសមាគ៌ា
សុចរិតត្រឹមត្រូវ ។

ហៃអស់កុមារ សព្វគ្រប់រូបា ត្រូវតែយកផ្លូវ
ព្រះធម៌ជាច្បាប់ ទុកជាសំពៅ សម្រាប់នាំទៅ
ភពសុខសួស្តី ។

ខំហាត់ពត់ខ្លួន ចិត្តឱ្យនឹងខ្លួន តាមផ្លូវប្រពៃ
រៀបចំឫកពា ឱ្យបានថ្លាថ្លៃ សមតាមប្រពៃ
ណីខ្មែរតទៅ ។

រៀនបទរៀនបាទ កំកោងហួសខ្នាត កុំភ្លាត់ហួសផ្លូវ
កុំភ្លើតកុំភ្លើនភ្លេចម៉ែ កុំប្រែភ្លេចឪ ឃើញចាស់សក់ស្កូវ
ពុំត្រូវមើលងាយ ។

ព្រះធម៌នេះថ្លៃ អ្នករៀនសព្វថ្ងៃ ប្រឹងកុំរាយមាយ
បើអ្នកប្រព្រឹត្ត នឹងបានផលក្រៃ សុខសួស្តីសេរី
ជ័យជោគដល់ប្រាណ ។

ហេតុនេះកុមារ ត្រូវតែប្រាថ្នា រៀនយកឱ្យបាន

នូវធម៌មិប្រពៃ នាំឱ្យសុខសាន្ត គ្រប់រូបគ្រប់ប្រាណ
កុំមានធុញទ្រាន់ ។

បើអ្នករៀនហើយ ត្រូវកុំកន្តើយ គប្បីរួសរាន់
ប្រតិបត្តិហ្មត់ចត់ សុចរិតជាឈ្នាន់ សម្រាប់អ្នកជាន់
ឈានដល់និញ្វន ។

# គុណព្រះរតនត្រៃ ៣ ប្រការ

១- ព្រះពុទ្ធត្រាស់ដឹងប្រពៃ ដោយព្រះអង្គឯងមុន ហើយទ្រង់ប្រដៅអ្នកដទៃឱ្យដឹងជាខាងក្រោយ ។

២- ព្រះធម៌រក្សាអ្នកប្រតិបត្តិ មិនឱ្យធ្លាក់ទៅក្នុងទីអាក្រក់ផ្សេងៗ ។

៣- ព្រះសង្ឃលោកប្រតិបត្តិល្អ តាមពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធ ហើយប្រដៅអ្នកដទៃឱ្យធ្វើតាមផង ។

ព្រះរតនត្រៃទាំង៣ គឺព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ មានគុណច្រើនជាអនេកអនន្តណាស់ មិនអាចនឹងគណនាឱ្យចប់សព្វគ្រប់បានឡើយ ។ អ្នកប្រាជ្ញផ្នែកខាងពុទ្ធនិយមបានប្រៀបធៀបថា បើយើងនឹងយកដែនដីធ្វើជាក្រដាស យកទឹកក្នុងមហាសមុទ្រធ្វើជាទឹកសរសេរ យកផ្កាយធ្វើជាស្លាបប៉ាក្កា យកភ្នំធ្វើជាដងប៉ាក្កា ដើម្បីសរសេរពណ៌នាអំពីគុណព្រះរតនត្រៃ ដោយការចារឹកជាតួអក្សរ លុះតែអស់គ្រឿងទាំងនោះ ក៏មិនអស់គុណព្រះរតនត្រៃបីនោះឡើយ ។

ហេតុនេះយើងខ្ញុំជាអ្នករៀបរៀង សូមដកយកតែគុណព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ដែលអ្នកកាន់ព្រះពុទ្ធសាសនាធ្លាប់បានសូត្ររំលឹកក្នុងពិធីបុណ្យផ្សេងៗ និងក្នុងពេលនមស្សការ ថ្វាយបង្គំនៅក្នុងវត្តអារាមជាដើម ជាសេចក្ដីសម្រាយដើម្បីងាយស្រួលដល់អ្នកសិក្សាដូចតទៅនេះ ។

# សូត្ររំលឹកគុណព្រះពុទ្ធរតនៈ

នមោតស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស (៣ចប់) វីកិរិយា នមស្សការថ្វាយបង្គំ នៃខ្ញុំព្រះករុណា ចូរមានដល់ព្រះដ៏មានព្រះភាគអង្គនោះ ព្រះអង្គជាព្រះអរហន្តដ៏ប្រសើរ ទ្រង់ត្រាស់ដឹងនូវញេយ្យធម៌ទាំងពួង ដោយប្រពៃចំពោះព្រះអង្គឥតមានគ្រូអាចារ្យណាប្រដៅព្រះអង្គឡើយ ។ (ក្រាបថ្វាយបង្គំម្តង)

ឥតិបិសោភគវាអរហំ ព្រះដ៏មានព្រះភាគអង្គនោះ ទ្រង់ព្រះនាមថា "អរហំ" ព្រោះ ព្រះអង្គ ឆ្ងាយចាកសឹកសត្រូវពោលគឺកិលេស ព្រមទាំងវាសនា គឺកាយបយោគ និងវចីបយោគ "សម្មាសម្ពុទ្ធោ" ទ្រង់ព្រះនាមថា "សម្មាសម្ពុទ្ធោ" ព្រោះព្រះអង្គត្រាស់ដឹងនូវញេយ្យធម៌ទាំងពួង ដោយប្រពៃចំពោះព្រះអង្គឥតមានគ្រូអាចារ្យណាប្រដៅព្រះអង្គឡើយ ។

វិជ្ជាចរណសម្បន្នោ ទ្រង់ព្រះនាមថា វិជ្ជាចរណសម្បន្នោ ព្រោះព្រះអង្គបរិបូណ៌ដោយវិជ្ជា៣ និងវិជ្ជា៨ និងចរណៈ១៥ សុគតោ ទ្រង់ព្រះនាមថា "សុគតោ" ព្រោះព្រះអង្គជាដំណើរល្អយាងទៅកាន់សុន្ទរស្ថាន គឺអមតៈ មហានិព្វាន លោកវិទូ ទ្រង់ព្រះនាមថា "លោកវិទូ" ព្រោះព្រះអង្គជ្រាបច្បាស់នូវត្រៃលោកអនុត្តរោ ទ្រង់ព្រះនាមថា "អនុត្តរោ" ព្រោះព្រះអង្គប្រសើរ ដោយសីលាទិគុណរកបុគ្គលណាមួយស្មើជាងគ្មាន បុរិសទម្មសារថិ ទ្រង់ព្រះនាមថា "បុរិសទម្មសារថិ" ព្រោះព្រះអង្គ ជាអ្នកទូន្មាននូវបុរសដែលមានឧបនិស្ស័យ គួរនឹងទូន្មានបានសត្ថាទេវមនុស្សានំ ទ្រង់ព្រះនាមថា "សត្ថាទេវមនុស្សានំ" ព្រោះព្រះអង្គជា សាស្ត្រាចារ្យនៃទេវតា និងមនុស្សទាំងឡាយ ។ ពុទ្ធោ ទ្រង់ព្រះនាមថា "ពុទ្ធោ" ព្រោះព្រះអង្គត្រាស់ដឹងនូវចតុរារិយសច្ច ហើយញុំាំងអ្នកដទៃឱ្យត្រាស់ដឹងផង ភគវា ទ្រង់ព្រះនាម "ភគវា" ព្រោះព្រះអង្គមានដំណើរទៅ កាន់ត្រៃភពខ្ជាក់ចោលហើយ គឺថាព្រះអង្គមិនត្រឡប់កើតទៀតឡើយ ។ (ក្រាបថ្វាយបង្គំម្តង )

# សូត្ររំលឹកគុណព្រះធម្មរតនៈ

"ស្វាក្ខាតោ ភគវតាធម្មោ" ព្រះបរិយត្តិធម៌ គឺព្រះត្រៃបិដកជាធម៌ គឺព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់សម្តែងហើយដោយល្អ "ធម្មោ" ព្រះនព្វលោ កុត្តរធម៌មាន ៩ប្រការ គឺមគ្គ៤ ផល៤ និព្វាន១ "សន្ទិដ្ឋិកោ" ជាធម៌ គឺព្រះអរិយបុគ្គលទាំងពួងដឹងពិតឃើញពិត ដោយបច្ចវេក្ខណញ្ញាណ គឺថានឹងបានដឹងដោយស្តាប់ ដោយជឿបុគ្គលដទៃនោះៗក៏ទេ គឺឃើញច្បាស់ដោយខ្លួនឯង "អកាលិកោ" ជាធម៌ឱ្យនូវផលមិនរង់ចាំកាល គឺថាបើព្រះអរិយមគ្គកើតឡើងហើយ ព្រះអរិយផល ក៏កើតក្នុងលំដាប់គ្នាមិនបានឃឹតយូរឡើយ "ឯហិបស្សិកោ" ជាធម៌គួរដល់ ឯហិបស្សវិធី គឺថាបើព្រះអរិយបុគ្គលដែលបានសម្រេចមគ្គផលហើយ ក៏គួរនឹងហៅបុគ្គលដទៃឱ្យចូលមកមើលបាន "ឱបនយិកោ" ជាធម៌គឺព្រះអរិយបុគ្គលគប្បីបង្អោនចូលមកទុកក្នុងខ្លួន ដោយអំណាចភាវនា "បច្ចត្តំវេទិតព្វោវិញ្ញូហិ" ជាធម៌ គឺអ្នកប្រាជ្ញទាំងឡាយមានឧប្បដិតញ្ញូបុគ្គលជាដើម គប្បីដឹង គប្បីឃើញច្បាស់ក្នុងចិត្តនៃខ្លួន។ (ក្រាបថ្វាយបង្គំម្តង)

# សូត្ររំលឹកគុណព្រះសង្ឃរតនៈ

សុបដិបន្នោ ភគវតោ សាវកសង្ឃោ ព្រះសង្ឃជាសាវ័កនៃព្រះដ៏មានព្រះភាគ លោកប្រតិបត្តិហើយដោយប្រពៃ គឺប្រតិបត្តិតាមគន្លងព្រះនព្វលោកុត្តរធម៌ "ឧជុបដិ-បន្នោ ភគវតោ សាវកសង្ឃោ" ព្រះសង្ឃជាសាវ័កនៃព្រះដ៏មានព្រះភាគ លោកប្រតិបត្តិដោយត្រង់ គឺប្រតិបត្តិជាមជ្ឈិមបដិបទា "ញាយបដិបន្នោ ភគវតោ សាវកសង្ឃោ" ព្រះសង្ឃជាសាវ័កនៃព្រះដ៏មានព្រះភាគ លោកប្រតិបត្តិដ៏សមគួរដល់ សាមីចិកម្ម គឺប្រតិបត្តិគួរដល់សីល សមាធិ បញ្ញា "យទិទំ ចត្តារិ បុរិសយុគានិ" ព្រះសង្ឃឯណា បើរាបជាគូនៃបុរសទាំងឡាយមាន ៤គូ គឺព្រះសង្ឃដែលបានសម្រេចនូវសោតាបត្តិមគ្គ និងសោតាបត្តិផល ជាគូ១ សកិទាគាមិមគ្គ និងសកិទាគាមិផលជាគូ១ អនាគាមិមគ្គ និងអនាគាមិផលជាគូ១ អរហត្តមគ្គ និងអរហត្តផលជាគូ១ "អដ្ឋបុរិសបុគ្គលា" បើរាប់រឿងជាបុរសបុគ្គលមាន៨ គឺព្រះសង្ឃដែលបានសម្រេចនូវ សោត្តាបត្តិមគ្គ១ សោត្តាបត្តិផល១ សកិទាគាមិមគ្គ១ សកិទាគាមិផល១ អនាគាមិមគ្គ១ អនាគាមិផល១ អរហត្តមគ្គ១ អរហត្តផល១ "ឯស ភគវតោ សាវកសង្ឃោ ព្រះសង្ឃទាំងនោះជាសង្ឃសាវ័កនៃព្រះដ៏មានព្រះភាគ "អាហុនេយ្យោ" លោកគួរទទួលនូវ ចតុប្បច្ច័យដែលបុគ្គលឧទ្ទិសចំពោះអ្នកមានសីល ហើយនាំមកអំពីចម្ងាយបង្អោនចូលមកបូជា "បាហុ- នេយ្យោ" លោកគួរទទួលនូវអាគន្តុកទាន គឺទានដែលបុគ្គលតាក់តែង ដើម្បីញាតិ និងមិត្ត ដែលមកអំពីទិសផ្សេងៗ ហើយបង្អោនចូលមកបូជា "ទក្ខិណេយ្យោ" លោកគួរទទួលនូវទាន ដែលបុគ្គលជឿនូវកម្ម និងផលហើយបូជា "អញ្ជលិករណីយោ" លោកគួរដល់អញ្ជលិកម្មដែល សត្វលោកគប្បីធ្វើ "អនុត្តរំ បុញ្ញក្ខេត្តំ លោកស្ស" លោកជាបុញ្ញក្ខេត្ត គឺជាទីដុះឡើងនៃពូជ គឺបុណ្យនៃសត្វលោករកខេត្តដទៃក្រៃលែងជាងគ្មាន ។ ( ក្រាបថ្វាយបង្គំម្តង )

# មាតិកាធម៌


បកិណ្ណកសង្ខេប ............................................................ i

បុព្វកថា ............................................................ ii

អារម្ភកថា "កំណាព្យ" ............................................................ iii

គុណព្រះរតនៈត្រៃ ៣ប្រការ ............................................................ v

សូត្ររំលឹកគុណព្រះពុទ្ធរតនៈ ............................................................ vi

សូត្ររំលឹកគុណព្រះធម្មរតនៈ ............................................................ vii

សូត្ររំលឹកគុណព្រះសង្ឃរតនៈ ............................................................ viii

មាតិកាធម៌ ............................................................ ix

១ : ឧបការធម៌ ............................................................ ១

២ : លោកបាលធម៌ ............................................................ ១

៣ : បុគ្គលរកបានដោយកម្រ ............................................................ ២

៤ : ធម៌មាន ២ ប្រការ ............................................................ ៣

៥ : សទ្ធា ............................................................ ៣

៦ : លក្ខណៈរបស់សទ្ធា ............................................................ ៤

៧ : ធម៌ធ្វើឱ្យល្អ ............................................................ ៤

៨ : បញ្ញា ............................................................ ៥

៩ : ឱវាទរបស់ព្រះពុទ្ធ ............................................................ ៦

១០ : អកុសលមូល ............................................................ ៦

១១ : កុសលមូល ............................................................ ៧

១២ : សាមញ្ញលក្ខណៈ .............................................. ៨
១៣ : វ័យ ៣ ប្រការ .............................................. ៩
១៤ : វត្ថុបរិភោគមិនឆ្អែត .......................................... ៩
១៥ : ស្រវឹង ........................................................ ១០
១៦ : លក្ខណៈមនុស្សឧស្សាហ៍ .................................. ១១
១៧ : ព្រះរតនៈត្រៃ .................................................. ១២
១៨ : ព្រះពុទ្ធទ្រង់ប្រដៅ .............................................. ១២
១៩ : ទុច្ចរិត ........................................................ ១៤
២០ : សុចរិត ........................................................ ១៥
២១ : សប្បុរិសបញ្ញត្តិ .............................................. ១៥
២២ : បុញ្ញកិរិយាវត្ថុ .............................................. ១៦
២៣ : វុឌ្ឍិធម៌ ........................................................ ១៧
២៤ : អគតិ ........................................................ ១៨
២៥ : បធានៈ ........................................................ ១៩
២៦ : អធិដ្ឋានធម៌ .................................................. ១៩
២៧ : ឥទ្ធិបាទធម៌ .................................................. ២០
២៨ : ព្រហ្មវិហារធម៌ .............................................. ២១
២៩ : លក្ខណៈមិនក្រោធ .......................................... ២១
៣០ : គួរធ្វើសេចក្ដីមិនប្រមាទក្នុងទី ៤ ឋាន .................... ២២
៣១ : ធម៌នាំឱ្យកើតជាអ្នកប្រាជ្ញ .................................. ២៣

៣២ : មិត្តមិនគួរសេពគប់ .......................................... ២៤
៣៣ : មិត្តគួរសេពគប់ .............................................. ២៥
៣៤ : ទិដ្ឋសម្បទាយិកត្ថៈ .......................................... ២៦
៣៥ : អន្តរាយរបស់អ្នកសិក្សា ៤ .................................. ២៧
៣៦ : អារក្ខកម្មដ្ឋាន .................................................. ២៨
៣៧ : អានិសង្សខន្តី .................................................. ២៩
៣៨ : នីវរណធម៌ ..................................................... ៣០
៣៩ : អនន្តរិយកម្ម .................................................. ៣១
៤០ : វេសារជ្ជករណធម៌ ............................................. ៣២
៤១ : ផលមនុស្សខ្ជិលដោយលំដាប់ ៦ប្រការ ................... ៣៣
៤២ : សប្បុរិសធម៌ .................................................. ៣៥

## ឧបការធម៌ដែលមានឧបការច្រើនមាន ២ ប្រការ

១- សតិស្មារតី-សេចក្ដីនឹកឃើញ។

២- សម្បជញ្ញៈ- សេចក្ដីដឹងខ្លួន។

ធម៌ទាំងឡាយដែលព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់សំដែងឡើង សុទ្ធតែមានឧបការៈច្រើនទាំងអស់។ តែក្នុងទីនេះ ខ្ញុំចោះយកតែសតិ និងសម្បជញ្ញៈនេះមកតាំងជាប្រមុខ ព្រោះសតិ និងសម្បជញ្ញៈ ធម៌នេះបើបានកើតឡើងហើយ គុណធម៌ដទៃទៀតដែលមិនទាន់បានកើតឡើង រមែងកើតឡើងបាន បើបានកើតឡើងហើយ ក៏រឹងរឹតតែចម្រើនឡើងទៀត។ បើបុគ្គលណាមួយ ដែលមានសតិ និងសតិសម្បជញ្ញៈ បុគ្គលនោះតែងបរិបូណ៌ ដោយគុណធម៌ផ្សេងៗដូចជា សទ្ធា សីលៈ ហិរិ ឱត្តប្បៈ ចាគៈ បញ្ញាជាដើម។

សតិ និងសម្បជញ្ញៈនេះ បើបុគ្គលណាមានហើយ ហាក់ដូចជាមានអ្នកណានាំផ្លូវឱ្យដើរ ត្រូវតាមគន្លងសេចក្ដីសុខចម្រើន។

សតិ និងសម្បជញ្ញៈ ជាធម៌មានឧបការៈច្រើន ដូចអធិប្បាយមកដោយសង្ខេបនេះ។

## លោកបាលធម៌ គឺធម៌គ្រប់គ្រងលោកមាន ២ ប្រការ

១-ហិរិ : សេចក្ដីខ្មាសបាប។

២-ឱត្តប្ប : សេចក្ដីក្រែងខ្លាចបាប។

លោកក្នុងទីនេះសំដៅយកសត្វលោក គឺមនុស្សយើងដែលតែងតែវិនាសអន្តរាយដោយប្រការផ្សេងៗនេះឯង។

ឯធម៌សំដៅយកច្បាប់សម្រាប់ឃុំគ្រងលោកឱ្យមានសេចក្ដីសុខចម្រើន ពាក្យពីរម៉ាត់នេះរួមចូលគ្នាហៅថា លោកបាលធម៌មានពីរប្រការ។

ហិរិៈ សេចក្ដីខ្មាសបាប គឺយើងនឹកឃើញការខ្មាសអំពើទុច្ចរិតដោយកាយ វាចា ចិត្តជាដើម ។

ឱត្តប្ប ៈ សេចក្ដីក្រែងខ្លាចបាប គឺយើងនឹកតក់ស្លុត ឬខ្លាចក្រែងនូវអំពើទុច្ចរិត ដោយកាយ វាចា ចិត្តជាដើម ។ ព្រោះហិរិនេះ ជាអជ្ឈត្តសមុដ្ឋាន ដែលជាហេតុមាននៅខាងក្នុងនាំឱ្យកើតឡើង ។ បុគ្គលណាមួយ កាលបើបានពិចារណាហេតុ ៤យ៉ាងគឺ ជាតិ វ័យ សេចក្ដីក្លៀវក្លា និងការចេះដឹងរបស់ខ្លួនហើយ បុគ្គលនោះមិនហ៊ានធ្វើបាបទាំងឡាយ មានបាណាតិបាត ការសម្លាប់សត្វជាដើម ។

## បុគ្គលរកបានដោយកម្រមាន ២ ប្រការ

១- បុព្វការី អ្នកធ្វើឧបការៈមុន ។

២- កតញ្ញូកតវេទី អ្នកដឹងឧបការៈដែលលោកបានធ្វើហើយ ធ្វើតបវិញ

បុព្វការី អ្នកធ្វើឧបការៈមុន បានដល់ឪពុកម្ដាយ និងគ្រូជាដើម ដែលបានធ្វើគុណូបការៈ ដល់កូន ឬសិស្ស បុគ្គលជំពូកនេះរកបានដោយកម្រណាស់ ទោះបីយើងមានប្រាក់វាល់លាន ក៏យើងពុំអាចទៅរកទិញដូរឪពុកម្ដាយបង្កើត ឬគ្រូពីទីណាឱ្យបានប្រាកដដូចជា ឪពុកម្ដាយ ឬគ្រូរបស់យើងមុននោះបានឡើយ ។

កតញ្ញូកតវេទី អ្នកដឹងឧបការៈ ដែលលោកធ្វើហើយ ធ្វើតបវិញ បានដល់កូន ឬសិស្ស ដែលជាអ្នកបានទទួលនូវគុណបំណាច់ពីឪពុកម្ដាយ ឬគ្រូរបស់ខ្លួន ហើយកម្រនឹងដឹងគុណ ដោយធ្វើបដិការៈតបគុណដល់គាត់វិញ ។

## ធម៌ ២ ប្រការ

១- កុសលធម៌- ធម៌ជាកុសល ។

២- អកុសលធម៌- ធម៌ជាអកុសល ។

ធម៌ជាកុសល បានដល់សេចក្តីសុចរិតល្អបរិសុទ្ធដោយកាយ វាចា ចិត្តមិនប្រើអំពើឃោរឃៅកាប់សម្លាប់ មិននិយាយពាក្យភូតភរកុហក់បោកប្រាស និយាយតែពាក្យដែលមានផលប្រយោជន៍ល្អ មានសន្តានចិត្តសុច្ចរិតត្រឹមត្រូវប៉ុណ្ណោះជាដើម ហៅថាកុសលធម៌ ។

អកុសលធម៌ បានដល់ការប្រព្រឹត្តិអំពើអាក្រក់ដោយកាយ វាចា ចិត្ត មានការកាប់ សម្លាប់ មនុស្ស សត្វ លួចទ្រព្យសម្បត្តិ ប្រព្រឹត្តខុសប្រពៃណី ប្រពន្ធកូនប្តី អ្នកដទៃ និយាយកុហក់បោកប្រាស់ ឱ្យគេខូចប្រយោជន៍ ដោយសារខ្លួនមានចិត្តគំនិតអាក្រក់ ចង់តែបៀតបៀនឱ្យគេវិនាស និងគំនុំគុំគួន ព្យាបាទអ្នកដទៃប៉ុណ្ណោះជាដើម ហៅថាអកុសលធម៌ ។

## សទ្ធា ២ ប្រការ

១- លោកិយសទ្ធា ការជឿជាប់នៅក្នុងលោក ឬជឿប្រាសចាកបញ្ញា ។

២- លោកកុត្តរសទ្ធា ការជឿប្រកបដោយបញ្ញា ឬជឿឆ្លងផុតចាកលោក ។

ដែលហៅថាលោកិយសទ្ធា គឺបានដល់សទ្ធារបស់បថុជន ដែលមានការកម្រើកញាប់ញ័រ ជាសទ្ធាដែលប្រាកចាកបញ្ញាអាចឃ្លេងឃ្លោងទៅតាមអារម្មណ៍ផ្សេងៗ ដែលប៉ះទង្គិចដល់ចិត្ត ។

លោកុត្តរៈសទ្ធា គឺជាសទ្ធាលោកុត្តរៈបានដល់សទ្ធាព្រះអរិយៈជាសទ្ធាប្រកបដោយបញ្ញា ជឿឆ្លងផុតចាកលោក មិនញាប់ញ័រឃ្លេងឃ្លោង សទ្ធាលោកុត្តរៈមានលក្ខណៈ ៤យ៉ាងគឺ

១-ជឿកម្ម ២-ជឿផល ៣-ជឿថាសត្វមានកម្មដែលខ្លួនធ្វើជារបស់ខ្លួន ៤-ជឿញាណរបស់ព្រះតថាគត ។

## សទ្ធាមានលក្ខណៈ ២ ប្រការ

១- សទ្ធបានលក្ខណសទ្ធា មានសេចក្ដីជឿថាលក្ខណៈ ។

២- ឱតប្បនលក្ខណសទ្ធាមានកិរិយាស្ទង់មើលហេតុផល ហើយទើបធ្វើជាលក្ខណៈ ។

សទ្ធបានលក្ខណសទ្ធា មានសេចក្ដីជឿថាលក្ខណៈគឺសំដៅយកផ្លូវចិត្ត ដែលជឿតាម ហើយចុះសម្រុងទៅលើអ្វីមួយដែលខ្លួនបានឃើញ បានឮ បានស្ដាប់ និងបានគិត ហៅថា សទ្ធបាន លក្ខណសទ្ធា ។

ឱតប្បនលក្ខណសទ្ធា គឺការជឿដោយពិចារណារកហេតុផលជាមុន ទើបធ្វើជាជំនឿ ដែលមិនមែនចេះតែជឿដោយគ្រាន់តែឮគេថា ឬដោយបានឃើញភ្លាមៗនោះទេ ពិចារណារកហេតុផលឱ្យដឹងថា តើមូលហេតុដូចម្ដេច បន្ទាប់ទៅនឹងឱ្យផលដូចម្ដេចទៀត លុះពិចារណាឃើញច្បាស់ថា ពិតជាត្រឹមត្រូវគួរធ្វើ ទើបធ្វើតាមប៉ុណ្ណោះជាដើម ហៅថាឱតប្បនលក្ខណសទ្ធា ។

## ធម៌ធ្វើឱ្យល្អ ២ ប្រការ

១- ខន្តិ សេចក្ដីអត់ធន់ ។

២- សោរច្ចៈ សេចក្ដីស្ងប់ស្ងៀម ។

ខន្តិ សេចក្ដីអត់ធន់ គឺអត់ធន់ចំពោះទុក្ខដែលជាមូលហេតុនាំឱ្យកើតចិត្តអាក្រក់ ៣ យ៉ាងគឺ

១- អត់ធន់ក្នុងចំណង់គ្រប់យ៉ាងដែលកើតឡើងក្នុងទ្វារទាំង៦ ។

២- អត់ធន់ចំពោះសេចក្ដីទុក្ខ ដែលនាំឱ្យកើតក្រោធខឹងតាមពាក្យបរម្បវាទ ដែលបុគ្គលដទៃស្ដីថារិះគន់ ឬត្មះតិះដៀល ។

៣- អត់ធន់ចំពោះសេចក្ដីទុក្ខ ដែលជាហេតុនាំឱ្យកើតសេចក្ដីវង្វេង បានខាងអត់ធន់នឹងទុក្ខវេទនាផ្សេងៗ ដែលកើតឡើងក្នុងកាយ និងចិត្តហើយមិនបណ្ដោយឱ្យលង់ក្នុងអំណាចទុក្ខវេទនាដែលនាំឱ្យទៅប្រព្រឹត្តអាក្រក់ ។

សោរច្ចៈ សេចក្ដីស្ងប់ស្ងៀម បានដល់ការធ្វើចិត្តឱ្យនឹងនក្នុងកាលដែលត្រូវអត់ធន់ ហាក់ដូចជាមិនភ្ញាក់ផ្អើលចំពោះហេតុការផ្សេងៗ ដែលកើតឡើង ។

សោរច្ចៈនេះ សម្រាប់បំប៉នខន្តី ឱ្យរឹតតែល្អប្រសើរឡើង ។

## <u>បញ្ញាមាន ២ ប្រការ</u>

១- លោកិយបញ្ញា បញ្ញាលោកជាបថុជន ។

២- លោកុត្តរបញ្ញា បញ្ញលោកុត្តរៈ ។

លោកិយបញ្ញា សំដៅយកបញ្ញារបស់មនុស្សបថុជនដែលនៅមានកិលេស និងតណ្ហា បញ្ញានេះអាចផ្ទុះធ្លាយបានតែសភាវធម៌ ដែលធ្វើឱ្យសម្រេចប្រយោជន៏ក្នុងលោកនេះរហូត ព្រហ្មលោកជាទីបំផុត ។

លោកុត្តរៈបញ្ញា គឺជាបញ្ញារបស់ព្រះអរិយបុគ្គលមានព្រះសម្មាសម្ពុទ្ធជាដើមជាបញ្ញា ដែលអាចលះកាត់កិលេស តណ្ហាទាំងពួង ហើយធ្វើឱ្យបានសម្រេចព្រះនិព្វានជាទីបំផុត ។

# ឱវាទរបស់ព្រះពុទ្ធ ៣ ប្រការ

១- សព្វបាបស្សអករណំ : មិនឱ្យធ្វើអំពើបាបទាំងពួង ។

២- កុសលស្សូបសម្បទា : ឱ្យសន្សំកុសលទាំងពួង ។

៣- សចិត្តបរិយោទបនំ : ត្រូវជម្រះចិត្តរបស់ខ្លួនឱ្យស្អាត ។

សព្វបាបស្សអករណំមិនឱ្យធ្វើអំពើបាបទាំងពួង គឺឱ្យវៀរចាកនូវទុច្ចរិត ការប្រព្រឹត្តិអាក្រក់ដោយកាយ វាចា ចិត្ត មានការសម្លាប់សត្វ លួចទ្រព្យគេ លួចប្រពន្ធកូនប្ដីអ្នកដទៃ និយាយភូតកុហក និងគំនិតបៀតបៀនសត្វ និងអ្នកដទៃ ។

កុសលស្សូបសម្បទា ឱ្យសន្សំកុសល គឺការញ៉ាំងកុសលឱ្យដល់ព្រមសំដៅទៅរកសុចរិត ៣យ៉ាងគឺ កាយសុចរិត វចីសុចរិត មនោសុចរិត ប្រព្រឹត្តល្អខាងផ្លូវកាយ ល្អខាងផ្លូវវាចា និងល្អខាងផ្លូវចិត្ត ។

សចិត្តបរិយោទបនំ ជម្រះចិត្តរបស់ខ្លួនឱ្យស្អាតបានដល់ជម្រះចិត្តឱ្យស្អាតផូរផង់ចាកគ្រឿងសៅហ្មង ចិត្តមានលោភៈ ទោសៈ មោហៈជាដើម ហើយតម្កល់ចិត្តឱ្យតាំងនៅក្នុងសមាធិ ធមិដ៏ប្រពៃ ។

# អកុសលមូល ៣ ប្រការ

១- លោភ : ចង់បានមិនចេះស្កប់ ។

២- ទោស : គិតប្រទូស្តគេ ។

៣- មោហ : វង្វេងមិនដឹងការពិត ។

លោភៈ ចង់បានមិនចេះស្កប់ បានដល់ការបណ្ដោយចិត្តឱ្យលង់ក្នុងអំណាចតណ្ហា ចង់បានហួសហេតុ រំលោភចំពោះទ្រព្យសម្បត្តិអ្នកដទៃ ប្រាសចាកសម្មាជីវៈជាដើម ។

ទោសៈ គិតប្រទូសគេ បានដល់ចិត្តប្រកបដោយសេចក្ដីក្រេវក្រោធឥតពិចារណា ចងគុំនុំ ព្យាបាទអ្នកដទៃ និងធ្វើឱ្យអ្នកដទៃវិនាសដោយសារខ្លួន ប្រាសចាកមេត្តា ករុណា មុទិតា ឧបេក្ខា។

មោហៈ វង្វេងមិនដឹងការពិត ល្ងិតល្ងង់មិនដឹងខុសត្រូវ មិនស្គាល់ហេតុផល ភ័ន្តច្រឡំ យល់ខុសជាត្រូវប្រាសចាកសមាធិ ភាវនាជាដើមហៅថា មោហៈ។

## កុសលមូល ៣ ប្រការ

១- អលោភៈ មិនចង់បានហួសហេតុ។

២- អទោសៈ មិនគិតប្រទូសគេ។

៣- អមោហៈ មិនវង្វេង។

អលោភៈ មិនចង់បានហួសហេតុ បានដល់ការមិនបណ្ដោយចិត្តឱ្យលង់ក្នុងអំណាចតណ្ហា មិនរំលោភចំពោះទ្រព្យសម្បត្តិអ្នកដទៃ រកស៊ីតាមសម្មាជីវៈជាដើម។

អទោសៈ មិនប្រទូសអ្នកដទៃ បានដល់ចិត្តដែលមិនក្រេវក្រោធខឹងឥតពិចារណា មិនចងគុំនុំព្យាបាទអ្នកដទៃ និងមិនធ្វើឱ្យអ្នកដទៃវិនាសដោយសារខ្លួន មានមេត្តា ករុណា មុទិតា ឧបេក្ខា។

អមោហៈ មិនវង្វេងល្ងិតល្ងង់ ស្គាល់នូវហេតុការណ៍ពិត ដឹងខុសត្រូវ តាំងចិត្តនៅក្នុងសមាធិ ភាវនាធម៌ ស្គាល់ធម៌ដែលនាំឱ្យវិនាស និងចម្រើនគ្រប់យ៉ាង។

# សមញ្ញលក្ខណៈ ៣ ប្រការ

១- អនិច្ចតា : សភាពជារបស់មិនទៀង។

២- ទុក្ខតា : សភាពជាទុក្ខ។

៣- អនត្តតា : សភាពជារបស់មិនមែនខ្លួន។

អនិច្ចតា : សភាវៈទាំងឡាយដែលកើតមានរូបរាងមកហើយ ទោះមនុស្ស សត្វ រុក្ខជាតិ របស់ទ្រព្យអ្វីៗក៏មិនទៀងទាត់សុទ្ធតែត្រូវវិនាសទៅវិញដូចៗគ្នា សូម្បីតែពេលវេលា ដែលវិនាសទៅវិញ ក៏មិនទៀងថាពេលណាដែរ ដូចពុទ្ធដីកាថាៈ អនិច្ចា វតសង្ខារ សង្ខារ ទាំងឡាយមិនទៀងទេ ឧប្បាទវយធម្មិនោឧប្បជ្ជិត្វា និរុជ្ឈន្តិ មានកិរិយាកើតឡើងហើយ តែងតែរលត់ទៅវិញជាធម្មតា។

ទុក្ខា សភាពជាទុក្ខតែងកើតឡើងមានរូប មានវិញ្ញាណ តែងមានសេចក្ដីទុក្ខជាប់តាមជានិច្ច មានសេចក្ដីទុក្ខចំពោះការឈឺចាប់គ្រាំគ្រា ចាស់ជរាមរណៈ និងទុក្ខចំពោះផលវិបាកផ្សេងៗ ឬសេចក្ដីប្រាថ្នាផ្សេងៗ ដែលមិនបានសម្រេចដូចបំណងជាដើម។

អនត្តតា រូបទាំងឡាយដែលកើតឡើងហើយ ទោះជារូបមនុស្ស សត្វក៏ដោយ សុទ្ធតែមិនមែនជារបស់ខ្លួនឡើយ។ ប្រសិនបើជារបស់យើងមែន យើងអាចឃាត់ឃាំងមិនឱ្យចាស់ជរា ឈឺស្លាប់ ឬរលត់រលាយទៅវិញបាន។ ដោយហេតុយើងឃាត់មិនបាននូវកើត ចាស់ ឈឺ ស្លាប់នេះហើយ ទើបព្រះពុទ្ធសំដែងថា មិនមែនជារបស់ខ្លួន។ សូម្បីតែរុក្ខជាតិក៏វិនាសទៅវិញដែរ។

# វ័យមាន ៣ ប្រការ

១- បឋមវ័យ : វ័យក្មេង

២- មជ្ឈិមវ័យ : វ័យកណ្តាល

៣- បច្ឆិមវ័យ : វ័យចុងក្រោយ

បឋមវ័យ វ័យក្មេងរាប់ពីអាយុ ១ឆ្នាំ ដល់ ៣៣ឆ្នាំ ដែលចាត់ជាវ័យសម្រាប់សិក្សាចំណេះវិជ្ជាផ្សេងៗ។

មជ្ឈិមវ័យ វ័យកណ្តាល រាប់ពីអាយុ ៣៤ឆ្នាំ ទៅដល់ ៦៤ឆ្នាំ គឺជាវ័យសម្រាប់សន្សំទ្រព្យ ស្វែងរកទ្រព្យសម្បត្តិផ្សេងៗ និងសន្សំកុសលធ្វើបុណ្យឱ្យទាន ទុកជាកំណប់ទ្រព្យសម្រាប់អនាគតជាតិ។

បច្ឆិមវ័យ វ័យចុងក្រោយ រាប់ចាប់ពីអាយុ ៦៥ឆ្នាំ រហូតតទៅ ជាវ័យសម្រាប់តាំងខ្លួនឱ្យឋិតនៅក្នុងសីល សមាធិ ភាវនា ស្វែងរកធម៌អាថ៌សម្រាប់ជាយានចម្លងជីវន្តទៅរកសុគតិភព។

ការបែងចែកអាយុទៅតាមវ័យទាំង ៣ ដូចបានរៀបរាប់មកនេះគឺ យោងទៅតាមកាលសម័យជាន់មុន ដែលមនុស្សមានអាយុដល់រយឆ្នាំ។ ឥឡូវនេះដែលមនុស្សមានអាយុថយចុះ ការបែងចែកនេះក៏ត្រូវតែគិតទៅតាមកាលៈទេសៈដែរ។

# វត្ថុបរិភោគមិនឆ្អែតមាន ៣ ប្រការ

១- និន្ទាយតិ : ការដេលមិនចេះឆ្អែត

២- សុរាមេរយៈ : សេពសុរាមេរ័យមិនចេះឆ្អែត

៣- មេថុនំ : ការសេពមេថុនធម្មមិនចេះឆ្អែត

និន្ទាយតិ : ឥរិយាបថក្នុងការដេករបស់សត្វលោក មិនមានកំណត់ចំនួនឆ្អែតគ្រប់គ្រាន់ ដូចការបរិភោគអាហារឡើយ ដូច្នេះសត្វលោកគួរកុំបណ្តោយឱ្យចិត្តលង់ក្នុង

ភាពងុយងប់ច្រើនហួសប្រមាណ ដែលជាហេតុនាំឱ្យកើតសេចក្តីខ្ជិលច្រអូស ប្រាសចាកសមាធិភាវនា។

សុរាមេរ័យ អ្នកប្រព្រឹត្តសេពសុរាមេរ័យ មិនមានអ្នកណាដែលកំណត់បានថាខ្លួនឆ្អែតដូចអាហារនោះទេ បើបណ្តោយចិត្តឱ្យធ្លាក់ចុះក្នុងចំណង នៃការសេពសុរា និងមេរ័យ ចំណង់នេះតែងទាក់ទាញបបួលចិត្ត ដោយឥតរើសពេលវេលា ឬឈប់សម្រាក។

មេថុនំ សេពមេថុនមិនចេះឆ្អែត មេថុនធម្ម ជាគ្រឿងទាក់ទាញចំណង់ចិត្តរបស់សត្វលោកធំបំផុត ទោះបើការសេពនោះ តាំងពីក្មេងរហូតខ្លួនចាស់ ក៏ចំណង់ក្នុងការសេពនៅតែមាន ដូច្នេះសត្វលោកគួរកុំបណ្តោយឱ្យចិត្តវង្វេងធ្លាក់ចូលទៅក្នុងចំណង់ដែលមិនមែនកំណត់ក្នុងការឆ្អែតនោះឡើយ។

## ស្រវឹង ៣ ប្រការ

១- យោព្វនមទោ ៖ ស្រវឹងវ័យ។

២- អរោគមទោ ៖ ស្រវឹងក្នុងខ្លួនថា ជាអ្នកគ្មានរោគ។

៣- ជាតិមទោ ៖ ស្រវឹងក្នុងជាតិមានយសស័ក្តិ ខ្ពង់ខ្ពស់ជាដើម។

យោព្វនមទោៈ ការស្រវឹងវ័យ បានដល់បុគ្គលមួយជំពូកដែលស្រលាញ់វ័យក្មេងហួសប្រមាណ ទោះបីចូលក្នុងមជ្ឈិមវ័យ ឬបច្ឆិមវ័យហើយក៏ដោយ នៅតែមានមានះថាខ្លួននៅក្មេងនៅឡើយ ការស្រវឹងវ័យរបៀបនេះអាចនាំឱ្យកើតបមាទធម៌ ភ្លេចគិតស្វែងរកការសិក្សា និងធ្វើកុសលធម៌ ឬធ្វើសមាធិភាវនាបាន។

អរោគមទោៈ ស្រវឹងក្នុងខ្លួនថាជាអ្នកគ្មានរោគ បុគ្គលជំពូកនេះដោយខ្លួនពុំទាន់បានជួបប្រទះនឹងរោគណាមួយមកបៀតបៀននៅឡើយ ក៏គិតថា "អាត្មាអញជាមនុស្សផុតចាករោគ"។ គំនិតនេះនឹងនាំឱ្យបុគ្គលនោះ កើតការធ្វេសប្រហែល បំភ្លេចចូលនូវ

ចំណោទសុខភាព និងអនាម័យជាដើម ការពិតរូបនីមួយៗ មិនអាចគេចពីជម្ងឺរោគាបានទេគ្រាន់តែឆាប់ ឬយូរប៉ុណ្ណោះ។

ជាតិមទោ : ស្រវឹងក្នុងជាតិមានយសស័ក្តិខ្ពង់ខ្ពស់ជាដើម បុគ្គលប្រភេទនេះដោយខ្លួនមានឋានន្តរស័ក្តិបុណ្យខ្ពង់ខ្ពស់ ក៏ស្រវឹងនឹងអំណាចបុណ្យស័ក្តិរបស់ខ្លួន ហើយភ្លេចគិតដល់អនិច្ចលក្ខណៈធម៌ យកអំណាចបុណ្យស័ក្តិនោះមកលុបបំបាត់សុជីវធម៌ ភ្លេចគិតដល់ញាតិ មិត្តជិតខាង។ ការស្រវឹងបុណ្យស័ក្តិនោះ អាចឱ្យបុគ្គលអ្នកស្រវឹងភ្លេចគិតដល់ទាន សីល សមាធិ ភាវនាទាំងអស់។

## លក្ខណៈមនុស្សឧស្សាហ៍មាន ៣ ប្រការ

១- អនិក្ខិត្តធុរតា : ប្រញាប់ធ្វើធុរៈ ដែលកាន់ទុកមិនចោលធុរៈ។

២- អនិព្វិន្ទតា : ធ្វើការងារដែលមកដល់ដៃមិនបង្អង់យូរ។

៣- អសង្គរតា : ធ្វើការងារតាមវេលាមិនបង្អង់ថ្ងៃ។

អនិក្ខិត្តធុរតា : ប្រញាប់ធ្វើធុរៈដែលកាន់ទុកមិនចោលធុរៈនោះ បានដល់គោលគំនិតអ្វីមួយដែលគិតបម្រុងនឹងធ្វើ ឬកាតព្វកិច្ចអ្វីមួយដែលត្រូវធ្វើជាចាំបាច់នោះ មិនកាន់ទុកបោះបង់ចោល ប្រញាប់ប្រញាល់យកកិច្ចការនោះមកធ្វើភ្លាមៗហៅថា អនិក្ខិត្តធុរតា។

អនិព្វិន្ទតា : ធ្វើការងារដែលមកដល់ដៃមិនបង្អង់យូរ គឺកិច្ចការអ្វីៗដែលមាននៅចំពោះមុខហើយ ជាកិច្ចការដែលខ្លួនត្រូវធ្វើ មិនបង្អង់ទុកថាចាំពេលនេះ ពេលនោះ ឬថ្ងៃនេះ ថ្ងៃនោះទេ ចាប់ធ្វើភ្លាមៗហៅថា អនិព្វន្ទតា។

អសង្គរតា : ធ្វើការងារតាមពេលវេលាមិនបង្អង់ថ្ងៃ បានដល់ការធ្វើការងារទៅតាមពេលវេលាដែលត្រូវធ្វើ ហើយមិនបង្អង់ទុកទៅថ្ងៃក្រោយ បើកិច្ចការនោះត្រូវ

ធ្វើថ្ងៃណា ពេលនោះក៏ចាប់ធ្វើថ្ងៃនោះ ពេលនោះភ្លាមៗ មិនបណ្តែតបណ្តោយឱ្យយូរ ហួសពេលវេលា នេះហៅថាអសង្ករតា ។

## ព្រះរតនៈត្រៃមាន ៣ ប្រការ

១- ព្រះពុទ្ធ

២- ព្រះធម៌

៣- ព្រះសង្ឃ

អ្នកប្រៀនប្រដៅមនុស្ស សត្វទូទៅឱ្យប្រព្រឹត្តល្អដោយកាយ វាចា ចិត្តតាមធម៌វិន័យហៅថា ព្រះពុទ្ធ ព្រោះព្រះអង្គត្រាស់ដឹងនូវញេយ្យធម៌ទាំងពួងដោយប្រពៃ ចំពោះព្រះអង្គឥតមានគ្រូអាចារ្យណាប្រដៅព្រះអង្គឡើយ ។

ព្រះធម៌ ជាពាក្យប្រៀនប្រដៅរបស់ព្រះសម្មាសម្ពុទ្ធ ដែលព្រះអង្គបានត្រាស់សំដែងទុក ដើម្បីជាប្រយោជន៍ដល់មនុស្សសត្វទូទៅ ។

ព្រះសង្ឃ ជាអ្នកស្តាប់ពាក្យប្រៀនប្រដៅរបស់ព្រះសម្មាសម្ពុទ្ធ ហើយបានផ្សាយពាក្យប្រៀនប្រដៅនោះ ដល់ពុទ្ធបរិស័ទ្ធឱ្យដើរតាមគន្លងជាមជ្ឈិមាបដិបទាផ្លូវកណ្តាល ដើម្បីសម្រេចមគ្គផលទាំងឡាយមានសោតាបដិមគ្គ និងសោតាបដិផលជាដើម ។

## ព្រះពុទ្ធទ្រង់ប្រដៅដោយធម៌ ៣ ប្រការ

១-អភិញ្ញាយ : ទ្រង់ប្រដៅដើម្បីឱ្យអ្នកស្តាប់ដឹងពិត ឃើញពិតក្នុងធម៌ដែលខ្លួនគួរដឹង គួរឃើញ ។

២-សនិទាន : ទ្រង់ប្រដៅដោយមានហេតុ គឺអ្នកស្តាប់បានត្រិះរិះតាមហើយរមែងឃើញពិត ។

៣-សប្បនិហារ : ទ្រង់ប្រដៅដោយសេចក្តីអស្ចារ្យ គឺកាលណាអ្នកស្តាប់បាន ប្រតិបត្តិតាម រមែងសម្រេចប្រយោជន៍តាមគួរដល់សេចក្តីប្រតិបត្តិរបស់ខ្លួន។

ព្រះសម្ពុទ្ធជាម្ចាស់ ទ្រង់បានទូន្មានសត្វលោក ដោយព្រះមហាករុណា ដល់ធំ-ទូលាយ ព្រោះព្រះអង្គមានបំណងចង់ឱ្យសត្វលោកបានសម្រេចផលប្រយោជន៍តាមពាក្យប្រៀនប្រដៅរបស់ព្រះអង្គ ទើបទ្រង់ប្រកាសធម៌មិនឱ្យជ្រុះហួសនិស្ស័យរបស់សត្វលោក ដើម្បីឱ្យត្រិះរិះយល់បានងាយ ដូចទ្រង់សម្តែងអំពីការកើត ចាស់ ឈឺ ស្លាប់ ជាធម៌សម្រាប់សត្វលោកទូទៅ។ "ព្រះអង្គទ្រង់ប្រដៅសត្វដោយមានហេតុ" បើអ្នកស្តាប់បានត្រិះរិះតាមពាក្យប្រៀនប្រដៅ រមែងឃើញពិត ព្រោះធម៌របស់ព្រះពុទ្ធជាម្ចាស់សុទ្ធតែមានហេតុផលទាំងអស់ ដូចទ្រង់សម្តែងនូវអរិយសច្ចធម៌ ៤ប្រការគឺ : តណ្ហាចំណង់ជាហេតុ នាំឱ្យកើតសេចក្តីទុក្ខលំបាកគ្រប់យ៉ាង មជ្ឈិម បដិបទា ជាផ្លូវកណ្តាលនាំឱ្យកើតការរំលត់ទុក្ខគ្រប់យ៉ាង ការប្រព្រឹត្តទុច្ចរិតនាំឱ្យកើតសេចក្តីទុក្ខលំបាកគ្រប់យ៉ាង ការប្រព្រឹត្តសុចរិតនាំឱ្យកើតសេចក្តីសុខក្សេមក្សាន្តគ្រប់យ៉ាង។ ម្យ៉ាងទៀតការសិក្សារៀនសូត្រនាំឱ្យកើតការចេះដឹងនូវវិជ្ជាផ្សេងៗ។

"ព្រះអង្គទ្រង់ប្រដៅយ៉ាងអស្ចារ្យ" កាលណាអ្នកស្តាប់ប្រតិបត្តិតាម រមែងបានទទួលប្រយោជន៍តាមសមគួរដល់សេចក្តីប្រតិបត្តិ ព្រោះព្រះអង្គយល់ច្បាស់នូវឆន្ទៈ អធ្យាស្រ័យ ឧបនិស្ស័យ និងភូមិនៃអ្នកដែលព្រះអង្គត្រូវប្រដៅនោះជាមុន ទើបទ្រង់ប្រដៅដោយធម៌សមគួរដល់និស្ស័យអ្នកនោះ។

# ទុច្ចរិត ការប្រព្រឹត្តិអាក្រក់មាន ៣ ប្រការ

១- កាយទុច្ចរិតៈ ការប្រព្រឹត្តិអាក្រក់ដោយកាយ ។

២- វចីទុច្ចរិតៈ ការប្រព្រឹត្តិអាក្រក់ដោយវាចា ។

៣- មនោទុច្ចរិតៈ ការប្រព្រឹត្តិអាក្រក់ដោយចិត្ត ។

អំពើអាក្រក់ទាំងឡាយណា ដែលកើតឡើងដោយកាយហៅថា កាយទុច្ចរិត មាន ៣យ៉ាង គឺៈ ១-បាណាតិបាតៈ ការសម្លាប់សត្វមានជីវិត ២-អទិន្នាទានៈ ការលួចទ្រព្យសម្បត្តិអ្នកដទៃ ៣-កាមេសុមិច្ឆាចារៈ ការប្រព្រឹត្តិខុសក្នុងមេថុនធម្ម ជាមួយស្ត្រីដែលមានគេថែរក្សា។ អំពើអាក្រក់ដែលបានកើតឡើងដោយសំដីហៅថា វចីទុច្ចរិតមាន ៤យ៉ាងគឺៈ ១-មុសាវាទៈ និយាយកុហក់អ្នកដទៃ ២-បិសុណាវាចាៈ សំដីញុះអ្នកដទៃ ៣-ផរុសវាទៈ ពោលពាក្យត្រគោះបោះបោកអ្នកដទៃ ៤-សម្ផប្បលាបៈ ពោលពាក្យរាយមាយផ្តេសផ្តាស ។

អំពើអាក្រក់ដែលកើតឡើងដោយចិត្តហៅថា មនោទុច្ចរិតមាន ៣គឺៈ ១-អភិជ្ឈាៈ សម្លឹងចង់បានទ្រព្យសម្បត្តិអ្នកដទៃ ២-ព្យាបាទៈ គំនុំគុំគួន និងធ្វើឱ្យអ្នកដទៃមានសេចក្តីវិនាស ៣-មិច្ឆាទិដ្ឋិៈ គំនិតយល់ខុសថាត្រូវ ។

ទុច្ចរិតទាំង ៣នោះ គឺជាអំពើដែលយើងត្រូវតែលះបង់ឱ្យផុតពីសន្តាន ព្រោះទុច្ចរិតទាំងនេះ ជាផ្លូវនាំយើងទៅកាន់សេចក្តីទុក្ខគ្រប់យ៉ាងក្នុងលោកនេះ និងលោកខាងមុខ ។

## សុចរិតការប្រព្រឹត្តិល្អមាន ៣ ប្រការ

១- កាយសុចរិតៈ ការប្រព្រឹត្តិល្អដោយកាយ ។

២- វចីសុចរិតៈ ការប្រព្រឹត្តល្អដោយវាចា ។

៣- មនោសុចរិតៈ ការប្រព្រឹត្តិល្អដោយចិត្ត ។

អំពើល្អដែលបានកើតឡើងដោយកាយហៅថា កាយសុចរិត មាន៣យ៉ាង គឺៈ ១-វៀរចាក ការសម្លាប់ជីវិតមានជីវិត ២-វៀរចាកការលួចទ្រព្យអ្នកដទៃ ៣-វៀរចាក ការប្រព្រឹត្តក្នុងមេថុនធម្ម ជាមួយបុរសស្ត្រីដែលគេថែរក្សា ។

អំពើល្អដែលកើតឡើងដោយវាចា ហៅថាវចីសុចរិតមាន ៤យ៉ាង គឺៈ ១-វៀរចាកការនិយាយកុហក់អ្នកដទៃ ២-វៀរចាកពាក្យញុះញង់អ្នកដទៃ ៣-វៀរចាកពោលពាក្យទ្រគោះបោះបោកដល់អ្នកដទៃ ៤- វៀរចាកពោលពាក្យរាយមាយផ្ដេសផ្ដាស ។

អំពើដែលកើតឡើងដោយចិត្តហៅថា មនោសុចរិត មាន ៣យ៉ាង គឺៈ ១-មិនសម្លឹងចង់បានទ្រព្យអ្នកដទៃ ២-មិនគុំនុំធ្វើឱ្យអ្នកដទៃវិនាស ៣-មានគំនិតយល់ត្រូវ ។

## សប្បុរិសប្បញ្ញត្តិ បញ្ញតិរបស់សប្បុរសមាន ៣ ប្រការ

១- ទានៈ ការឱ្យវត្ថុខ្លួនដល់អ្នកដទៃ ។

២- បព្វជ្ជាៈ ការកាន់ភេទជាអ្នកបួសដើម្បីជាឧបាយវៀរចាកធមិរបស់គ្រហស្ថ ។

៣- មាតាបិតុឧបដ្ឋានៈ ការប្រតិបត្តិមាតាបិតា ។

ការបញ្ញតិរបស់អ្នកមានសណ្ដានចិត្តស្ងប់ និងមានអធ្យាស្រ័យល្អ មានសេចក្ដីប្រព្រឹត្តរៀបរយត្រឹមត្រូវហៅថា "សប្បុរិសប្បត្តិ" ។

ការលះកាត់សេចក្ដីកំណាញ់របស់ខ្លួន រួចឱ្យជាទានដល់អ្នកដទៃ ដើម្បីជាមិត្តសម្បត្តិ ។ ការវាចាកធមិរបស់គ្រហស្ថ មានការត្រេចត្រអាលក្នុងកាមគុណជាដើម ហើយក៏ចេញទៅបួសជាភិក្ខុសាមណេរ ដើម្បីប្រព្រឹត្តឱ្យខ្លួនបានស្ងប់ចាកកិលេសធមិទាំងពួង ។

មាតាបិតាជាអ្នកបង្កើតកូនប្រុសស្រី និងចិញ្ចឹមបីបាច់ថែរក្សាគ្រប់ពេលថ្ងៃ-យប់ លោកតែងមានព្រហ្មវិហារធម៌ដល់កូនប្រុសស្រីជានិច្ច។ ហេតុនេះកូនប្រុសស្រីត្រូវតបស្នង សងគុណលោកវិញដោយបការៈផ្សេងៗ មានជូនអាហារសម្រាប់បរិភោគជាដើម។

## បុញ្ញកិរិយាវត្ថុ វត្ថុជាទីញ៉ាំងការបំពេញបុណ្យមាន ៣ ប្រការ

១- ទានមយៈ បុណ្យសម្រេចដោយការឱ្យទាន។

២- សីលមយៈ បុណ្យសម្រេចដោយការរក្សាសីល។

៣- ភាវនាមយៈ បុណ្យសម្រេចដោយការចម្រើនភាវនា។

ទានមយៈ បុណ្យសម្រេចដោយការឱ្យទានមានការបរិចាកទ្រព្យសម្បត្តិរបស់ខ្លួនដល់អ្នកដទៃ ដូចជាមាតាបិតា ភិក្ខុសាមណេរ ចាស់ព្រឹទ្ធាចារ្យ អ្នកកម្សត់ទុគតិជាដើម។

សីលមយៈ បុណ្យសម្រេចដោយការរក្សាសីល បានដល់ការរក្សាកាយ វាចា ចិត្តសុភាពរាបសារ មានការវៀរចាកការកាប់សម្លាប់ និងបៀតបៀនជីវិតមនុស្ស សត្វទូទៅជាដើម។

ភាវនាមយៈ បុណ្យសម្រេចដោយការចម្រើនភាវនាបញ្ញា ការយល់គិតដល់សង្ខារ ជាផ្លូវធ្វើចិត្តឱ្យសុខស្ងប់ជាដើម។

# វុឌ្ឍិធម៌ ធម៌ធ្វើឱ្យចម្រើនមាន ៤ ប្រការ

១- សប្បុរិស្សូបសំសេវៈ ការសេពគប់សប្បុរស។

២- សទ្ធម្មស្សវនៈ ការស្តាប់ប្រៀនប្រដៅរបស់លោកដោយគោរព។

៣- យោនិសោបនសិការៈ ការត្រិះរិះឱ្យស្គាល់របស់ល្អ ឬអាក្រក់ដោយ បញ្ញា។

៤- ធម្មានុធម្មប្បដិបត្តិៈ ការប្រតិបត្តិធម៌ដ៏សមគួរដល់ធម៌ដែលបានឃើញមក ហើយ។

វុឌ្ឍិៈ សេចក្តីចម្រើន បើបុគ្គលណាម្នាក់ចង់បានសេចក្តីចម្រើនក្នុងផ្លូវលោក និង ផ្លូវធម៌ ត្រូវមានធម៌ ៤ប្រការនេះ។

ការសេពគប់សប្បុរស អ្នកប្រព្រឹត្តអំពើល្អដោយកាយ វាចា ចិត្ត ទោះជាបុរស ស្ត្រីក្តី គ្រហស្ថ បព្វជិតក្តី មិនថាជាតិណា ត្រកូលណាទេឱ្យតែមានសន្តានចិត្តស្ងប់ចាក បាបទាំងពួង មានព្រះពុទ្ធជាដើម។

ហេតុនេះ បើយើងបានសេពគប់ជាមួយលោកអ្នកសប្បុរស ដូចបានអធិប្បាយ មកនេះ យើងតែងបានស្តាប់ពាក្យប្រៀនប្រដៅរបស់លោក។ កាលបើយើងបានស្តាប់ ពាក្យប្រៀនប្រដៅរបស់លោក ដោយគោរពហើយត្រូវត្រិះរិះឱ្យដឹងហេតុផល លុះយើង បានត្រិះរិះត្រឹមត្រូវហើយ យើងត្រូវមានការប្រតិបត្តិដ៏សមគួរ ដល់សេចក្តីត្រិះរិះឃើញ នោះទៀត ទើបបានសម្រេចផលប្រយោជន៍ពិតប្រាកដ។

# អគតិ ការលម្អៀងមាន ៤ ប្រការ

១- ឆន្ទាគតិៈ ការលម្អៀងព្រោះស្រឡាញ់។

២- ទោសាគតិៈ ការលម្អៀងព្រោះស្អប់។

៣- មោហាគតិៈ ការលម្អៀងព្រោះល្ងង់។

៤- ភយាគតិៈ ការលម្អៀងព្រោះខ្លាច។

ដំណើរការណ៍មិនយុត្តិធម៌មិត្រឹមត្រូវ ឬថ្លឹងមិនស្មើដោយការលម្អៀង ៤យ៉ាងដូចតទៅនេះ បុគ្គលណាម្នាក់ជាអ្នកគ្រប់គ្រងអ្នកដទៃ មានការលម្អៀងព្រោះស្រឡាញ់ពេញចិត្ត ទោះអ្នកដែលខ្លួនស្រឡាញ់នោះ បានប្រព្រឹត្តិខុសមិនត្រឹមត្រូវយ៉ាងណាក៏ដោយ ក៏មិនខុសដែរព្រោះ ស្រឡាញ់អ្នកនោះ។

ការលម្អៀងព្រោះស្អប់ បុគ្គលណាម្នាក់ជាអ្នកគ្រប់គ្រងអ្នកដទៃ មានសេចក្ដីលម្អៀង ដូចជាលោកគ្រូមួយរូប មានសិស្សពីរនាក់ សិស្សទាំងពីរនោះបានប្រព្រឹត្តិអំពើអ្វីមួយខុសដូចគ្នា តែលោកគ្រូបានដាក់ទោសដល់សិស្សម្នាក់ដែលខ្លួនស្អប់ប៉ុណ្ណោះ។

ការលម្អៀងព្រោះល្ងង់ បុគ្គលណាម្នាក់ជាអ្នកគ្រប់គ្រងអ្នកដទៃ ដូចជាមាតាបិតាដែលគ្រាន់តែឮពាក្យអ្នកដទៃនិយាយថាកូនរបស់ខ្លួនប្រព្រឹត្តិខុសយ៉ាងនេះ យ៉ាងនោះមិនពិចារណា រកហេតុផលឱ្យបានត្រឹមត្រូវ ក៏ស្រាប់តែវាយដំកូនរបស់ខ្លួនដោយសេចក្ដីល្ងង់ខ្លៅ។

ការលម្អៀងព្រោះខ្លាច បុគ្គលណាម្នាក់ជាអ្នកគ្រប់គ្រងអ្នកដទៃ មានការខ្លាចអាចក្លាយទៅជាមនុស្សប្រកបដោយអយុត្តិធម៌ ដូចលោកគ្រូម្នាក់មានសិស្សពីរនាក់ សិស្សម្នាក់ជាអ្នកមានត្រកូលខ្ពង់ខ្ពស់ និងទ្រព្យសម្បត្តិស្ដុកស្ដម្ភ សិស្សម្នាក់ទៀតមានត្រកូលថោកទាប ទីទ័លក្រ សិស្សទាំងពីរនេះបានប្រព្រឹត្តខុសដូចគ្នា តែលោកគ្រូដាក់ទោសដល់សិស្សម្នាក់ដែលក្រនោះ ព្រោះខ្លាចត្រកូល និងទ្រព្យសម្បត្តិរបស់គេ។

## បធានៈ សេចក្តីព្យាយាមមាន ៤ ប្រការ

១- សំវរប្បធានសៈ សេចក្តីព្យាយាមប្រយ័ត្នមិនឱ្យបាបកើតឡើងបានក្នុងសន្តានចិត្ត ។

២- មយានប្បធានៈ សេចក្តីព្យាយាមលះបង់បាបដែលបានកើតឡើងហើយ ។

៣- ភាវនាបធានៈ សេចក្តីព្យាយាមញុំាងកុសលឱ្យកើតឡើងក្នុងសន្តានចិត្ត ។

៤- អនុរក្ខនាបធានៈ សេចក្តីព្យាយាមរក្សាកុសលដែលកើតឡើងហើយនោះមិនឱ្យសាបសូន្យទៅវិញ ។

ការប្រុងប្រយ័ត្នអំពើអាក្រក់គ្រប់យ៉ាង "១" តាមទ្វារទាំងបី ដែលផុះឡើងក្នុងកាយ វាចា ចិត្តបាន ។

អំពើអាក្រក់ដែលខ្លួនបានធ្វើរួចមកហើយ ត្រូវព្យាយាមលះបង់ចោល មិនឱ្យមានក្នុងទ្វារទាំងបី តទៅទៀត ។

អំពើល្អដែលខ្លួនមិនទាន់បានធ្វើឱ្យកើតមានឡើង ក៏ត្រូវតែព្យាយាមធ្វើ ឬគិតរកឧបាយណាមួយធ្វើឱ្យកើតមានឡើង ។

អំពើល្អដែលខ្លួនបានធ្វើរួចមកហើយ ត្រូវព្យាយាមរក្សាការពារទុកមិនបណ្តោយឱ្យបាត់បង់ទៅវិញ ដោយហេតុណាមួយ ។

## អធិដ្ឋានធម៌ ធម៌ដែលគួរតាំងទុកក្នុងចិត្តមាន ៤ ប្រការ

១- បញ្ញាៈ ការដឹងអ្វីៗ ដែលគួរដឹង ។

២- សច្ចៈ សេចក្តីពិតក្នុងចិត្តដែលយើងត្រូវធ្វើ ក៏ធ្វើពិត ។

៣- ចាគៈ ការលះបង់របស់អ្វីដែលជាសត្រូវដល់សេចក្តីពិតក្នុងចិត្ត ។

៤- ឧបសមៈ សេចក្តីស្ងប់ចាកអារម្មណ៍ដែលជាសត្រូវដល់សេចក្តីស្ងប់ ។

ការដឹងនូវសភាវៈ ពិតទូទៅដូចជាការដឹងថា "បាប" ជាអំពើអាក្រក់ត្រូវតែលះបង់ចោល "បុណ្យ" ជាកុសលធម៌ត្រូវតែសន្សំធ្វើបំពេញឱ្យមានឡើង។

ម្យ៉ាងទៀត ការដឹងនូវវិជ្ជាថា ជាទ្រព្យដ៏ប្រសើរត្រូវតែស្វះស្វែង ឧស្សាហ៍រៀនសូត្រឱ្យបានគ្រប់រូប មិនថាក្មេង ចាស់ ប្រុសស្រី។

សេចក្ដីពិតក្នុងចិត្តរបស់ខ្លួន គឺបុគ្គលណាមួយបើដឹងពិតថា អ្វីដែលជាប្រយោជន៍ដល់ខ្លួន និងអ្នកដទៃ ក៏ត្រូវតែធ្វើពិតតាមសមត្ថភាពរបស់ខ្លួនដោយមិនឡើយណាយឡើយ។

ការលះបង់អ្វីដែលជាសត្រូវដល់សេចក្ដីពិត ដូចជាការប្រព្រឹត្តិអាក្រក់ដោយកាយ វាចា ចិត្តដែលប្រកបដោយ លោភៈ ទោសៈ មោហៈ និងកោសជ្ជៈ សេចក្ដីខ្ជិលច្រអូស មិនឧស្សាហ៍រៀនសូត្រនូវវិជ្ជាផ្សេងៗ។

សេចក្ដីស្ងប់ចាករោគៈ ទោសៈ មោហៈ ដែលជាគ្រឿងធ្វើឱ្យល្អក់ចិត្ត និងអន្ទះអន្ទែងចិត្តហៅថា "ឧបសម"។

## ឥទ្ធិបាទធម៌ ជាជំហរឱ្យសម្រេចប្រយោជន៍មាន ៤ ប្រការ

១- ឆន្ទៈ ការចូលចិត្តស្រឡាញ់ការងារ។

២- វិរិយៈ ការព្យាយាមប្រកបការងារ។

៣- ចិត្តៈ ការយកចិត្តទុកដាក់ក្នុងការងារ។

៤- វិមំសាៈ ការត្រិះរិះរកហេតុក្នុងការងារ។

ធម៌ជាជំហរឱ្យសម្រេចប្រយោជន៍គ្រប់យ៉ាង តែងទាក់ទងហេតុផលដល់គ្នានិងគ្នា គឺការចូលចិត្តស្រឡាញ់ការងារ ជាហេតុនាំឱ្យកើតសេចក្ដីព្យាយាមធ្វើការងារដែលខ្លួនចូលចិត្តធ្វើនោះ បើសេចក្ដីព្យាយាមកើតឡើងហើយ ការយកចិត្តទុកដាក់ក្នុងការងារនោះៗ ក៏កើតឡើងដែរ បើមានធម៌ទាំងបីប្រការនេះកើតឡើងហើយ ត្រូវតែ

មានការសាកល្បងរិះរកហេតុផលក្នុងការងារនោះឱ្យឃើញថាគួរធ្វើ ឬមិនគួរធ្វើ ទើបសម្រេចប្រយោជន៍ក្នុងសេចក្ដីប្រាថ្នាបាន ។

## ព្រហ្មវិហារធម៌ ធម៌ជាទីលំនៅរបស់ព្រហ្មមាន ៤ ប្រការ

១- មេត្តា: សេចក្ដីប្រាថ្នាចង់ឱ្យអ្នកដទៃបានសុខ ។

២- ករុណា: សេចក្ដីអាណិតគិតជួយឱ្យអ្នកដទៃរួចចាកទុក្ខ ។

៣- មុទិតា: សេចក្ដីត្រេកអរតាមក្នុងពេលដែលអ្នកដទៃបានសុខ ។

៤- ឧបេក្ខា: សេចក្ដីតាំងចិត្តជាកណ្ដាល មិនសោមនស្ស ឬទោមនុស្សក្នុងពេលដែលអ្នកដទៃមានវិបត្តិ ។

ក្នុងទីនេះ ព្រហ្មវិហារធម៌សំដៅយកធម៌របស់អ្នកគ្រប់គ្រងបុគ្គលដទៃ ដូចមាតាបិតា ជាអ្នកគ្រប់គ្រងបុត្រធីតា គ្រូបាចារ្យជាអ្នកគ្រប់គ្រងសិស្សានុសិស្ស ឧបជ្ឈាយាចារ្យជាអ្នកគ្រប់គ្រងសទ្ធិវិហារិក និងអន្តេវាសិក: ប្រមុខរដ្ឋជាអ្នកគ្រប់គ្រងពលរដ្ឋក្នុងប្រទេសរបស់ខ្លួនជាដើម ។ លោកអ្នកទាំងនេះ សុទ្ធតែត្រូវប្រកបដោយព្រហ្មវិហារធម៌ទាំង ៤នេះ ទើបសម្រេចផល ។

## លក្ខណ:មិនក្រោធមាន ៤ ប្រការ

១- នអក្កោច្ឆិ: មិនជេរគេវិញ ។

២- នអវធិ: មិនប្រទុស្ដរាយគេវិញ ។

៣- នអជិនិ: មិនកោងដាក់គេវិញ ។

៤- នអហាសិ: មិនប្លន់គេវិញ ។

នអក្កោច្ឆិ: មិនជេរគេវិញ បានដល់ការមិនជេរប្រទេចតបទៅលើបុគ្គលដែលជេរចំពោះខ្លួន ព្រោះថាវិវាទបើយើងជេរប្រទេចតបទៅវិញទៅមកអាចធ្វើឱ្យចិត្តរឹតតែ

មានកំហឹង ពុះពោរឡើង ផ្ទុយទៅវិញ បើយើងអត់ធ្មត់ហើយយកមេត្តា ករុណា មុទិតា មកផ្សាយទៅលើអ្នកជេរ នោះនឹងអាចធ្វើឱ្យចិត្តយើងទោរទន់បាត់ក្រោធខឹងទៅបាន។

នអវធិៈ មិនប្រទូស្តរាយគេវិញ គឺមិនប្រើកំហឹងវាយតប់ទៅលើបុគ្គលដែលប្រទុស្តមករកខ្លួន ដូច្នេះយើងនឹងអាចឈ្នះអ្នកប្រទុស្តរាយនោះបានដោយផ្លូវចិត្តទៀតផង ដូចព្រះពុទ្ធដីកាថា "អកោធេជិនាកោធំ" ឈ្នះខឹងដោយមិនខឹង។

នអធិនិៈ មិនកោងដាក់គេវិញ បើបុគ្គលណាធ្វើឫកព្រហើនកោង ចំពោះយើងៗគប្បីធ្វើឫកសុភាពរាបសារតបទៅវិញ ដូច្នេះចិត្តយើងក៏នឹងទន់ចុះមិនប្រកាន់ខឹង ទាំងអ្នកដែលកោងដាក់យើង ក៏ត្រូវនឹងចុះចាញ់ ហើយប្រើឫកពារសុភាពរាបសារដាក់យើងវិញដែរ។

នអហោសិៈ មិនប្លន់គេវិញ បានដល់មិនប្រើអំពើចោរកម្មទៅប្លន់ ទ្រព្យសម្បត្តិបុគ្គល ដែលបានប្លន់ទ្រព្យសម្បត្តិរបស់យើង ហើយធ្វើចិត្តឱ្យនឹងនពិចារណារកហេតុផលនៃកុសល និងអកុសលឱ្យឃើញច្បាស់លាស់ ដូច្នេះចិត្តក៏នឹងទោរទន់ឈប់ខឹងទៅបាន។

## គួរធ្វើសេចក្តីមិនប្រមាទក្នុងទី ៤ ស្ថាន

១- កាយទុច្ចរិតប្បហានៈ លះបង់កាយទុច្ចរិតប្រព្រឹត្តកាយសុចរិត។

២- វចីទុច្ចរិតប្បហានៈ លះបង់វចីទុច្ចរិតប្រព្រឹត្តវចីសុច្ចរិត។

៣- មនោទុច្ចរិតប្បហានៈ លះបង់មនោទុច្ចរិត ហើយប្រព្រឹត្តមនោសុច្ចរិត។

៤- មិច្ឆាទិដ្ឋិប្បហានៈ លះបង់ការយល់ខុសទាំងពួង ហើយប្រព្រឹត្តតាមសេចក្តីយល់ឃើញត្រូវវិញ។

# ធម៌នាំឱ្យកើតទៅជាអ្នកប្រាជ្ញមាន ៤ ប្រការ

១- សុតៈ ស្ដាប់

២- ចិន្តៈ គិត

៣- បុច្ឆាៈ សួរ

៤- លិខិតៈ កត់សំគាល់

សុតៈ "ស្ដាប់" អ្នកដែលមានការស្ដាប់ច្រើន បានដល់ការស្ដាប់សម្ដីរបស់សប្បុរស ដែលជាគ្រូបាធ្យាយនី ណែនាំពន្យល់នូវចំណេះវិជ្ជា ឬហេតុផលផ្សេងៗ ដែលមានប្រយោជន៍ផ្ទាល់ខ្លួន ព្រោះអ្នកស្ដាប់បើស្ដាប់ច្រើន នឹងនាំឱ្យចេះច្រើនដែរ។

ចិន្តៈ "គិត" ពាក្យដែលយើងបានស្ដាប់រួចមកហើយ ដូចមានអធិប្បាយក្នុងអង្គទី១នោះ ក្រោយពីស្ដាប់ ត្រូវយកមកត្រិះរិះពិចារណារកហេតុផលឱ្យឃើញច្បាស់លាស់ជាបន្តទៅទៀត។

បុច្ឆាៈ "សួរ" កាលបើត្រិះរិះគិតទៅហើយមិនធ្លុះធ្លាយមានសេចក្ដីសង្ស័យកន្លែងណា ត្រូវដេញដោលសួរឱ្យបានដឹងច្បាស់ក្នុងគំនិតដែលយើងសង្ស័យនោះតទៅទៀត។

លិខិតៈ "កត់សំគាល់" ក្រោយពីស្ដាប់យល់ជាក់ ឬសួរដឹងឬសគល់ច្បាស់លាស់ហើយ ត្រូវកត់ចំណាំទុកក្នុងចិត្ត ឬសរសេរកត់ត្រាទុកក្នុងសៀវភៅសម្រាប់សិក្សាតទៅទៀត។

១- ឥត្ថីធុត្តៈ ជាអ្នកលេងស្រី បានដល់បុគ្គលដែលងប់ងុលក្នុងគ្រឿងកាមគុណមិនឆ្អែតឆ្អន់ ការល្មោភក្នុងគ្រឿងកាមនេះ អាចធ្វើឱ្យអាយុតិច រាងកាយទ្រុឌទ្រោមបង្កបង្កើតរោគា និងខាតបង់ទ្រព្យសម្បត្តិទៀតផង។

២- សុរាធុត្តៈ ជាអ្នកលេងស្រា ពាក្យថាអ្នកលេងស្រា គឺសំដៅយកបុគ្គលដែលសេពសុរា និងមេរ័យ។ គ្រឿងស្រវឹងនេះ បើជនណាសេពញឹកញាប់ជាប់

ជានិច្ចនឹងនាំឱ្យខាតបង់ទ្រព្យសម្បត្តិ ដោយការទិញដូរ លុះស្រវឹងនឹងនាំឱ្យខ្ជិលរកស៊ី ធ្វើការងារ និងនាំឱ្យមានជម្ងឺដល់រាងកាយ ទីបំផុតអាយុក៏ថយចុះ។

៣- អក្ខធុត្តៈ ជាអ្នកលេងល្បែងភ្នាល់ ឬល្បែងស៊ីសង ល្បែងភ្នាល់ និងល្បែងស៊ីសងនេះ បើបុគ្គលណាប្រព្រឹត្តនឹងនាំឱ្យមានទោស ៦យ៉ាងគឺៈ ១-កាលណាឈ្នះ រមែងបង្កឱ្យកើតជាពៀរ ២-កាលណាចាញ់ រមែងសោកស្តាយទ្រព្យ ៣-ទ្រព្យ រមែងវិនាស ៤-និយាយអ្វីៗ គ្មានគេជឿពាក្យខ្លួន ៥-អ្នកផងទាំងពួងតែងមើលងាយ ៦-ពុំមានគេចង់ចងសម្ព័ន្ធជាមិត្រ។

៤- បាបមិត្តៈ យកមនុស្សអាក្រក់ជាមិត្ត ការសេពគប់ នឹងមនុស្សអាក្រក់ដែលចាត់ជាជំពូកជនពាលនោះ ជនប្រភេទនេះពុំដែលមានគំនិតល្អទេ ដូច្នេះកាលណា បើនិយាយដឹកនាំមិត្តភក្តិរបស់ខ្លួន ក៏ដឹកនាំតែផ្លូវអាក្រក់ដែរ។ ព្រោះការសេពគប់នឹងមនុស្សរបៀបណា ក៏អាចទៅជារបៀបនោះដូចគ្នា។

## មិត្តមិនគួរសេពគប់មាន ៤ ប្រការ

១- អញ្ញទត្ថុហរៈ មនុស្សឃើញតែខាងបានពីគេ គឺមនុស្សដែលសម្លឹងឃើញតែប្រយោជន៍ខ្លួនយកពីគេ បើអ្នកណាធ្វើប្រយោជន៍ អ្វីឱ្យដល់ខ្លួនៗ សប្បាយចិត្តណាស់ តែចំពោះខ្លួនឯងវិញ កំណាញ់ស្វិតពុំមានគំនិតគិតឃើញចែករំលែករបស់ទ្រព្យខ្លួនឱ្យទៅដល់អ្នកដទៃវិញឡើយ។

២- វចីបរមៈ មនុស្សល្អតែមាត់ បានដល់បុគ្គលដែលមានវាចាផ្អែមល្ហែមដែលស្តាប់ទៅ ហាក់ជាមនុស្សសុចរិតត្រឹមត្រូវ ឬមានសមានចិត្តស្មោះ តែតាម

ការពិត គំនិតក្នុងខ្លួនក្បត់ពីសម្តីដែលនិយាយទៅវិញ ដូចបុរាណថា "មាត់ធមិពោះយក្ស ឬដូចចុងដាវដែលលាបដោយទឹកឃ្មុំ" ។

៣- អនុប្បិភាណើៈ មនុស្សប្រចុប គឺមនុស្សដែលប្រចុបប្រចែងតែផ្គាប់ផ្គុន ដើម្បីសម្លឹងឃើញប្រយោជន៏ខ្លួននៅខាងមុខ មិនមែនផ្គាប់ផ្គុនដោយសន្តាន ចិត្តស្មោះត្រង់ពិត១ នោះទេ ។

៤- អបាយសហាយៈ មនុស្សដឹកនាំក្នុងផ្លូវវិនាស បានដល់បុគ្គលដែលនិយាយ ដឹកនាំក្នុងផ្លូវអាក្រក់មានការលួច ឆក់ លេងល្បែងស៊ីសង ឬសេពសុរា- មេរ័យជាដើម ហៅថាដឹកនាំក្នុងផ្លូវវិនាស បុគ្គលជំពូកនេះមិនគួរសេពគប់ ឡើយ ។

## មិត្តដែលគួរសេពគប់មាន ៤ ប្រការ

១- ឧបការមិត្តៈ មិត្តមានឧបការ គឺមិត្តមានលក្ខណៈដូចទៅនេះ

ក- ការពារមិត្តដែលមានសេចក្តីធ្វេសប្រហែស ។

ខ- ការពារទ្រព្យដែលមានសេចក្តីធ្វេសប្រហែស ។

ឃ- កាលបើមានភ័យអាចយកជាទីពឹងបាន កាលណាមានទុក្ខធុរៈកើតឡើង ជួយចេញទ្រព្យរំដោះទុក្ខមិត្ត និងឱ្យមិត្តខ្ចីលើសពីចំនួនដែលមិត្តសុំខ្ចី ។

២- សុខទុក្ខមិត្តៈ មិត្ររួមសុខទុក្ខ គឺមិត្រដែលមានលក្ខណៈដូចតទៅនេះ

ក- បញ្ចេញសម្តីកំបាំងរបស់ខ្លួនប្រាប់ដល់មិត្ត ។

ខ- បិទរឿងអាថ៌កំបាំងរបស់មិត្តមិនឱ្យសាយភាយបែកការទៅទៀត ។

គ- មិនលះបង់ចោលគ្នា ក្នុងគ្រាមានភ័យអន្តរាយ ។

ឃ- ស៊ូប្តូរជីវិតជាមួយមិត្រ ។

៣- អត្ថក្ខាយៈ មិត្រប្រាប់ផ្លូវប្រយោជន៏ឱ្យ គឺមិត្រដែលមានលក្ខណៈដូចតទៅនេះ :

ក- ហាមមិត្រមិនឱ្យធ្វើសេចក្តីអាក្រក់ ។

ខ- ដឹកនាំមិត្រឱ្យតាំងនៅសេចក្តីល្អ ។

គ- ដឹកនាំឱ្យបានស្តាប់សេចក្តីដែលមិនបានស្តាប់ ។

ឃ- ប្រាប់ផ្លូវសួគ៌ឱ្យស្តាប់ គឺផ្លូវដែលនាំទៅកាន់សេចក្តីសុខចម្រើន ។

## ទិដ្ឋធម្មិកត្ថៈ ប្រយោជន៍ក្នុងបច្ចុប្បន្ន មាន ៤ ប្រការ

១- ឧដ្ឋានសម្បទាៈ ការដល់ព្រមដោយសេចក្តីខ្នះខ្នែងក្នុងការងារ ។

២- អារក្ខសម្បទានៈ ការដល់ព្រមដោយការថែរក្សា ។

៣- កល្យាណមិត្តតាៈ ការសេពគប់ជាមួយមិត្តល្អ ។

៤- សមជីវិតាៈ ការចិញ្ចឹមជីវិតស្មើៗ ។

បុគ្គលស្វះស្វែងរកទ្រព្យសម្បត្តិ ត្រូវតែឧស្សាហ៍ព្យាយាមដោយកុំគិតថាព្រឹកពេក ល្ងាចពេក។ បើទ្រព្យសម្បត្តិដែលខ្លួនរកបានមកហើយ នោះត្រូវចេះថែរក្សាទុកដាក់ឱ្យគង់វង្សកុំឱ្យបាត់បង់ទៅដោយប្រការណាមួយ ។ កាលបើបានថែរក្សាទុកត្រឹមត្រូវហើយ ត្រូវស្វែងរកមិត្តល្អ ដែលអាចពឹងពាក់បាន ព្រោះមិត្តល្អតែងជួយគ្នាក្នុងផ្លូវត្រូវមិនគិតប្រយោជន៍ផ្ទាល់ខ្លួន ។ តែការសំខាន់មួយទៀត គឺយើងត្រូវចេះចាយវាយក្នុងកិច្ចការចិញ្ចឹមជីវិតដោយស្មើៗ ជានិច្ច ឬចេះសន្តាសឱ្យសមល្មមតាមលក្ខណៈគ្រួសាររបស់យើង ទើបបានសម្រេចដូចបំណងពិតប្រាកដ ។

# អន្តរាយរបស់អ្នកសិក្សាមាន ៤ ប្រការ

១- អត់ធនចំពោះពាក្យទូន្មាន មិនបានខ្ជិលធ្វើតាម ។

២- ជាមនុស្ស ឃើញតែការបរិភោគច្រើនហួសប្រមាណ អត់ធនសេចក្ដីស្រេកឃ្លានមិនបាន ។

៣- ត្រេកអរក្នុងកាមគុណ ចង់បានសេចក្ដីសប្បាយច្រើនហួសប្រមាណលើសពីលក្ខណៈរបស់សេក្ខាកាមកុលបុត្រ ។

៤- ការបណ្ដោយចិត្ត ឱ្យលង់ក្នុងល្បែងពាលាស្រីស្រា ប្រាសចាកភាពជាសិស្ស ។

ការអត់ទ្រាំចំពោះពាក្យទូន្មានមិនបាន ខ្ជិលធ្វើតាម បានសេចក្ដីថាកុលបុត្រ កុលធីតា អ្នកសិក្សារៀនសូត្រដែលមិនទាន់មានសេចក្ដីចេះដឹងនូវវិជ្ជាផ្សេងៗ និងមិនទាន់ចេះប្រព្រឹត្តតាមការសិក្សានៅឡើយ ។

ហេតុនេះ សិស្សានុសិស្សត្រូវតែមានការរៀនសូត្រអំពីសំណាក់គ្រូអាចារ្យ និងការដាស់តឿនអំពីមាតាបិតាជាដើម ។

ក្នុងការសិក្សានេះ តែងតែជួបប្រទះនឹងដំបូន្មាន ពាក្យប្រៀនប្រដៅ ស្ដីបន្ទោសខ្លះពីគ្រូអាចារ្យ ។

កុលបុត្រ កុលធីតាជាសិក្ខាកាម ជនណាឃើញតែការបរិភោគច្រើនហួសប្រមាណ មិនចេះអត់នឹងសេចក្ដីស្រេកឃ្លាន ជាមនុស្សគិតតែពីរឿងបរិភោគដែលជាហេតុនាំឱ្យកើតសេចក្ដីខ្ជិលច្រអូសគ្រប់បែបយ៉ាង និងអន្តរាយដល់ការសិក្សារៀនសូត្ររបស់ខ្លួន ។

កុលបុត្រ កុលធីតាណា ត្រេកត្រអាលក្នុងកាមគុណទាំង ៥ប្រការ ហ៊ឺហាសប្បាយ ក្នុងសម្លេង ក្លិន រស សម្ផស្ស កុលបុត្រ កុលធីតានេះមិនអាចសម្រេចនូវវិជ្ជាបានឡើយ ។

ការប្រព្រឹត្តអព្រហ្មចារិយធម៌នេះ កាលបើសិក្ខាកាមកុលបុត្រ កុលធីតា អ្នកប្រាថ្នាការរៀនសូត្រណាបានប្រព្រឹត្តឱ្យមាននៅក្នុងខ្លួនហើយ មិនអាចសម្រេចនូវវិជ្ជាផ្សេងៗ បានឡើយ ។

## អារក្ខកម្មដ្ឋាន ការតាំងចិត្តក្នុងអំពើដែលគួររក្សាជានិច្ច ៤ ប្រការ

១- ពុទ្ធានុស្សតិៈ សេចក្តីរំលឹកគុណព្រះពុទ្ធ ដែលមានក្នុងព្រះអង្គ និងគុណដែលទ្រង់សង្គ្រោះដល់មនុស្ស និងសត្វទូទៅ ។

២- មេត្តាៈ ការផ្សាយមេត្តាចិត្ត គិតឱ្យមនុស្សដូចគ្នា និងសត្វទាំងពួងឱ្យបានសុខគ្រប់រូប ។

៣- អសុភៈ ការពិចារណារាងកាយខ្លួន និងអ្នកដទៃឱ្យឃើញថា ជារបស់បដិកូល គួរខ្ពើម រអើម ហើយធ្វើខ្លួនឱ្យបានត្រឹមត្រូវ ។

៤- មរណស្សតិៈ ការនឹកដល់សេចក្តីស្លាប់ ដែលតែងតែមានដល់ខ្លួន និងអ្នកដទៃជានិច្ច ។

"ការនឹកឃើញគុណព្រះពុទ្ធ ដែលមានក្នុងព្រះអង្គ ចំពោះមនុស្ស សត្វទូទៅ" បើយើងនិយាយឱ្យងាយយល់ បានដល់ការចម្រើនពុទ្ធានុស្សតិ ជាប្រយោជន៍សម្រាប់រម្ងាប់ថិនមិទ្ធ ការងោកងុយ ដែលជាហេតុនាំឱ្យអស់នូវការឧស្សាហ៍ព្យាយាមក្នុងកិច្ចការគ្រប់បែបយ៉ាង ។

ការផ្សាយមេត្តាជាប្រយោជន៍ដល់មនុស្ស និងសត្វឱ្យប្រាសចាកទុក្ខភ័យពៀរវេរាគ្រប់ប្រការ ដើម្បីឱ្យមានសេចក្តីស្និទ្ធស្នាលដល់គ្នា និងគ្នា ។

ការពិចារណារូបរាងខ្លួន និងអ្នកដទៃឱ្យឃើញថាៈ ជារបស់បដិកូល គួរខ្ពើមនោះមានន័យជ្រាលជ្រៅណាស់ តែអ្នកនិពន្ធសូមអធិប្បាយឱ្យងាយយល់ថា បើបុគ្គលណាមួយបានពិចារណាឃើញរូបរាងថា ជារបស់គួរខ្ពើម ដូច្នេះយើងត្រូវតែប្រព្រឹត្តខ្លួនឱ្យបាន

ត្រឹមត្រូវល្អ ដើម្បីឈោងយកកេរ្តិ៍ឈ្មោះល្អនោះ ទើបឈ្មោះថាយើងធ្វើរូបរាងកាយមិនឱ្យទៅជារបស់ខ្ពើមរអើមវិញ។

ការនឹកឃើញសេចក្តីស្លាប់ដែលនឹងមានដល់ខ្លួនប្រាជក ដូច្នេះជាហេតុនាំឱ្យកុលបុត្រ កុលធីតា មានសេចក្តីព្យាយាមឧស្សាហ៍សិក្សារៀនសូត្រ និងប្រព្រឹត្តអំពើល្អគ្រប់វិស័យ ដើម្បីកិត្តិយស កេរ្តិ៍ឈ្មោះ និងជាគ្រឿងដាស់តឿនចិត្តសិស្សានុសិស្សឱ្យលះបង់នូវសេចក្តីខ្ជិលច្រអូសគ្រប់យ៉ាង។

## អានិសង្សខន្តី ៥ ប្រការ

១- បិយោមនាបោះ នឹងបានជាទីស្រឡាញ់រាប់អានរបស់ទេវតា និងមនុស្សទាំងអស់។

២- នវេរពហុលោះ នឹងមិនចម្រើនទៅដោយពៀរវេរា។

៣- នវជ្ជពហុលោះ នឹងមិនចម្រើនទៅដោយទោស។

៤- អសម្មូឡ្ហោ : នឹងមានស្មារតីមិនវង្វេងក្នុងសេក្តីស្លាប់។

៥- សុគតិ: ស្លាប់ហើយនឹងបានទៅកើតក្នុងស្ថានសួគ៌។

ពិយោមនាបោះ បុគ្គលដែលមានអំណត់អត់ធន់ មិនប្រកាន់ខឹងចំពោះទោសហេតុ ដែលចេញពីអ្នកដទៃមកលើខ្លួន ឬមិនប្រកាន់ខឹងចំពោះហេតុការណ៍អាក្រក់ល្អផ្សេងៗ នឹងមិនបណ្តោយមិត្រឱ្យលង់ក្នុងអំណាច ទោសធម៌ រមែងត្រូវបានជាទីរាប់អានរបស់មនុស្ស និងទេវតា។

នវេរពហុលោះ ពៀរវេរាដែលកើតមានឡើង បើបុគ្គលនីមួយៗ អាស្រ័យដោយចិត្ត ទោស ក្រេវក្រោធហើយចងគំនុំតបទៅវិញទៅមក បើបុគ្គលមានខន្តីខ្ជាប់ខ្ជួនមិនប្រកាន់ខឹង ចំពោះហេតុអាក្រក់ដែលកើតមានមកលើខ្លួន សេចក្តីអំណត់អត់ធន់នេះ

អាចនាំឱ្យចិត្តរបស់បុគ្គលនោះ មិនមានគំនុំចងពៀរទៅបានឡើយ ដូច្នេះពៀរវេរាតទៅអនាគតក៏គ្មានដែរ ។

នវជ្ជពហុលោៈ ទោសទណ្ឌតែងកើតឡើងទៅលើបុគ្គលដែលមានចិត្តទោសខឹង ហើយប្រទុស្តសារាយតបត បណ្តាលឱ្យកើតទៅជារឿងដុំកំភួនធ្លាក់ខ្លួនប្រព្រឹត្តបទមជ្ឈិម ឬឧក្រិដ្ឋផ្សេងៗ ផ្ទុយនឹងច្បាប់រដ្ឋ បើបុគ្គលណាលះទោសមិនខឹងតបត ចំពោះហេតុការណ៍អាក្រក់ ដែលកើតមកលើខ្លួន ទោសទណ្ឌដែលជាផលវិបាកអាក្រក់ ក៏មិនអាចកើតមានមកលើបុគ្គលនោះបានឡើយ ។

អសម្មុឡ្ហោៈ បុគ្គលដែលធ្លាប់មានសេចក្តីអំណត់អត់ធន់ ចំពោះហេតុការណ៍អាក្រក់ផ្សេងៗ ដែលធ្លាក់មកលើខ្លួន លុះដល់ជិតស្លាប់ក៏មិនមានការតក់ស្លុតចំពោះសេចក្តីស្លាប់នោះដែរ ព្រោះធ្លាប់បានហាត់ពត់ចិត្តចំពោះទុក្ខទោសគ្រោះថ្នាក់ទាំងឡាយរួចមកហើយ ដូច្នេះវេលាជិតស្លាប់អាចតម្កល់ចិត្តរបស់ខ្លួនឱ្យតាំងនៅក្នុងអារម្មណ៍ល្អបាន ។

សុគតិៈ បុគ្គលដែលមានខន្តីដ៏ល្អ លុះវេលាស្លាប់ទៅ នឹងបានទៅកើតក្នុងសុគតិភព ព្រោះជីវន្តរបស់បុគ្គលនោះមុននឹងស្លាប់មិនមានជាប់ជំពាក់ទៅលើអារម្មណ៍អាក្រក់ ជាចិត្តធ្លាប់ហាត់ពត់ក្នុងផ្លូវធម៌ដ៏ល្អប្រពៃៗនេះ ក៏អាចនាំឱ្យទៅកើតក្នុងសុគតិភព ។

## **នីវរណធម៌ ៥ ប្រការ**

១- កាមឆន្ទៈ ស្រឡាញ់ចូលចិត្តក្នុងអារម្មណ៍ គឺការស្រឡាញ់ចូលចិត្តក្នុងអារម្មណ៍ទាំងឡាយមានរូបារម្មណ៍ជាដើម ដែលជាទីគាប់ចិត្តធ្វើឱ្យចិត្តជាប់ជំពាក់ ។

២- ព្យាបាទៈ ចងចិត្តគំនុំ បានដល់ចងចិត្តគំនុំគុំគួនទៅលើអ្នកដទៃ ប៉ងព្យាបាទឱ្យគេវិនាសជាដើម ។

៣- ថីនមិទ្ធៈ ងោកងុយ គឺដំណើរដែលចិត្តរួញថយការងក់ងុយ ដែលធ្វើឱ្យស្ទះដំណើរសិក្សារៀនសូត្រ និងធ្វើឱ្យចិត្តពិចារណាវិបស្សនាសមាធិភាវនាមិនកើតទៀតផង។

៤- ឧទ្ធច្ចកុក្កុច្ចៈ ដំណើរចិត្តរាយមាយ គឺដំណើរចិត្តរាយមាយរសាប់រសល់រវើរវាយ មិននឹងក្នុងអារម្មណ៍ដែលត្រូវឈោងយក។

៥- វិចិកិច្ឆាៈ សេចក្តីសង្ស័យមិនដាច់ស្រេចទៅលើអ្វីៗ ដែលខ្លួនពិចារណាទៅហើយ នៅតែមិនអស់ មិនហើយក្នុងចិត្ត ចេះតែនៅមានសង្ស័យរហូត។

## អនន្តរិយកម្ម អំពើដ៏ធ្ងន់បំផុតមាន ៥ ប្រការ

១- មាតុឃាតៈ ការសម្លាប់មាតា។

២- បិតុឃាតៈ ការសម្លាប់បិតា។

៣- អរហន្តឃាតៈ ការសម្លាប់ព្រះអរហន្ត។

៤- លោហិតុប្បាទៈ ការប្រទុស្តព្រះពុទ្ធអង្គ រហូតដល់ញ៉ាំងព្រះលោហិតឱ្យពុះពោរ ឬចេញឈាម។

៥- សង្ឃភេទៈ ការញ៉ាំងសង្ឃឱ្យបែកបាក់គ្នា។

កម្មទាំង ៥យ៉ាងនេះ ជាអំពើធ្ងន់បំផុតរបស់អ្នកធ្វើ។ មាតាបិតាជាបុព្វការីមុនគេបង្អស់ដល់បុត្រធីតា បើបុគ្គលណាមួយហ៊ានសម្លាប់មាតាបិតារបស់ខ្លួនហើយ បុគ្គលនោះមុខជាហ៊ានសម្លាប់អ្នកដទៃទៀត ក្នុងពេលណាដែលខ្លួនមិនពេញចិត្ត។ អ្នកណាម្នាក់ហ៊ានប្រព្រឹត្តអំពើអាក្រក់ដ៏ធ្ងន់នេះ អ្នកនោះលោកឱ្យឈ្មោះថា បំផ្លាញកុសលវង្សរបស់ខ្លួនពិតប្រាកដ។

ព្រះអរហន្ត គឺលោកដែលផុតចាកកិលេសទាំងពួង ជាបុញ្ញខេត្ត រកខេត្តដទៃក្រៃលែងជាងគ្មានសីលធមិ ដ៏ខ្ពង់ខ្ពស់លើសមនុស្ស និងទេវតា បើបុគ្គលណាមួយហ៊ាន

សម្លាប់ព្រះអរហន្ត ឈ្មោះថាបំផ្លាញជនទូទៅ ព្រោះព្រះអរហន្តជាអ្នកបង្ហាញផ្លូវសុខចម្រើនដល់ប្រជាជនទាំងអស់ ។

ព្រះសម្មាសម្ពុទ្ធ ជាសាស្ត្រាចារ្យនៃមនុស្ស និងទេវតាទាំងឡាយ បើបុគ្គលណាហ៊ាន ប្រទុស្តព្រះសម្មាសម្ពុទ្ធឈ្មោះថា ប្រមាថមើលងាយព្រះសាស្តា អ្នកនោះចាត់ទុកដូចជា ហ៊ានប្រទុស្តចំពោះព្រះធម៌ ព្រះសង្ឃ ទេវតា និងមនុស្សទូទៅដែរ ។ ភិក្ខុអ្នកបំបែកសង្ឃបានសេចក្តីថា អ្នកញុះញង់ព្រះសង្ឃឱ្យបែកបាក់គ្នា ។

ម្យ៉ាងទៀត សង្ឃប្រែថាហ្វូង ឬបើពួកបុគ្គលណាហ៊ានញុះញង់បំបែកហ្វូង ឬពួកនៃមនុស្សដែលផ្តល់ប្រយោជន៍ដល់ប្រជាជនទូទៅ បុគ្គលនោះមានទោសប្រហាក់ប្រហែលនឹងបំបែកបំបាក់សង្ឃដែរ ។

## វេសារជ្ជករណធម៌ៈ ធម៌ធ្វើឱ្យក្លាហានមាន ៥ ប្រការ

១- សទ្ធាៈ ការជឿរបស់ដែលគួរជឿ ។

២- សីលៈ ការរក្សាកាយ វាចា ចិត្តឱ្យបានរៀបរយ ។

៣- ពាហុសច្ចៈ ការដឹងរបស់ដែលគួរដឹង ។

៤- វិរិយារម្ភៈ ប្រារព្ធនូវសេចក្តីព្យាយាម ។

៥- បញ្ញាៈ ការដឹងរបស់ដែលគួរដឹង ។

សទ្ធា ជំនឿរបស់ដែលគួរជឿ ជាគុណធម៌មួយសំខាន់បំផុត ដែលបុគ្គលគួរធ្វើឱ្យកើតមានឡើងក្នុងចិត្ត ព្រោះសទ្ធាទុកជាមិត្តមួយដ៏ល្អអាចជួយទាញយើងឱ្យមានជំនឿចំពោះការសិក្សាវិជ្ជាផ្សេងៗ ថាជាហេតុនាំឱ្យជីវិតមនុស្សរស់នៅមានសេចក្តីសុខ និងថ្លៃថ្នូររុងរឿង ។

សីលៈ ការរក្សាកាយវាចា ឱ្យរៀបរយមានសុភាពរាបសារ ប្រាសចាកទោស ដែលអ្នកប្រាជ្ញតែងតិះដៀល។ ទោះបីមានសីលនោះធ្វើអ្វី និយាយអ្វីក៏ដោយ តែងមានសេចក្តីក្លាហានមិនតក់ស្លុត។

ពាហុសច្ចៈ គឺអ្នកសិក្សាចេះដឹងសិល្បវិទ្យាច្រើន ហើយទ្រទ្រង់ចាំអត្ថមិនភ្លាំងភ្លាត់ក្នុងកិច្ចការដែលខ្លួនធ្វើ និងនិយាយ។

វិរិយរម្ភៈ ការប្រារព្ធនូវសេចក្តីព្យាយាមឱ្យបានមាំមួនបានដល់ការផ្តើមធ្វើកិច្ចការអ្វីមួយ ដោយសង្វាតមិនរុញរាចំពោះឧបសគ្គផ្សេងៗ។

បញ្ញាៈ ការដឹងរបស់ដែលគួរដឹង គឺដឹងនូវវិជ្ជាផ្លូវលោក ផ្លូវធម៌ស្គាល់បាបបុណ្យគុណទោស ប្រយោជន៍ និងមិនមែនប្រយោជន៍ជាដើម។

## ផលមនុស្សខ្ជិលដោយលំដាប់ ៦ ប្រការ

១- អលសស្ស កុតោ សិប្បំៈ មនុស្សខ្ជិលមិនជួបប្រទះវិជ្ជា ។

២- អសិប្បស្ស កុតោ ធនំៈ គ្មានវិជ្ជារកទ្រព្យមិនបាន។

៣- អធនស្ស កុតោ មិត្តំៈ គ្មានទ្រព្យគ្មានមិត្រ។

៤- អមិត្តស្ស កុតោ សុខំៈ គ្មានមិត្តតែងខ្វះសេចក្តីសុខ។

៥- អសុខស្ស កុតោ បុញ្ញំៈ គ្មានសេចក្តីសុខនឹងរកបុណ្យមិនបាន។

៦- អបុញ្ញស្ស កុតោ និព្វានំៈ គ្មានបុណ្យនឹងបណ្តុះព្រះនិព្វានមិនបាន។

អលសស្ស កុតោ សិប្បំៈ វិជ្ជាទាំងឡាយកើតឡើងដោយការឧស្សាហ៍ប្រឹងប្រែងរៀនសូត្រ រៀនតិចចេះតិច រៀនច្រើនចេះច្រើន បើចិត្តខ្ជិលច្រអូសមិនសិក្សារៀនសូត្រតើវិជ្ជា នឹងកើតឯងៗ ដូចម្តេចបាន។

អសិប្បស្ស កុតោ ធនំៈ ទ្រព្យសម្បត្តិតែងកើតឡើងអាស្រ័យលើវិជ្ជា បើយើងមានចំណេះវិជ្ជាក្នុងការរកទទួលទានតិច យើងក៏រកបានទ្រព្យតិច បើយើងចេះដឹងក្នុង

វិជ្ជាជីវៈច្រើន យើងក៏រកទ្រព្យបានច្រើន បើយើងគ្មានចំណេះវិជ្ជាចេះដឹងអ្វីទាំងអស់ក្នុងមុខរបរវិជ្ជាជីវៈ តើទ្រព្យសម្បត្តិនឹងកើតមានមកដូចម្ដេចបាន សូម្បីទ្រព្យសម្បត្តិដែលធ្លាប់មានមកជាកេរ្តិ៍មរតក នឹងត្រូវរលាយបាត់ទៅដែរ ដោយសារគ្មានវិជ្ជាចេះរក្សា និងបណ្ដុះបណ្ដាល ។

អគ្គនស្សកុតោមិត្តំៈ តាមធម្មតាជាទូទៅ តែកាលណាយើងមានទ្រព្យសម្បត្តិច្រើន អ្នកទាំងពួងតែងរាប់អានសេពគប់ចងជាមិត្តភក្តិ តែបើយើងធ្លាក់ខ្លួនក្នុងសភាពក្រីក្រដុនដាប គ្មានទ្រព្យសម្បត្តិវិញនោះ ប្រាកដជាពុំមានអ្នកណាគេរាប់អានយើងចងជាមិត្តឡើយ ។

អមិត្តស្សកុតោសុខំៈ សេចក្ដីសុខសាន្តតែងកើតមាន ក៏អាស្រ័យញាតិជាមិត្តៗនេះឯង ដែលអាចផ្ដល់សេចក្ដីសុខជួយទុក្ខធុរៈ និងការពារគ្រោះភ័យផ្សេងៗ បើគ្មានមិត្តវិញ តើសេចក្ដីសុខសាន្តកើតមកពីណា?

អសុខស្សកុតោបញ្ញំៈ ការសន្សំកុសលផលបុណ្យ ដែលអាចធ្វើទៅបានអាស្រ័យដោយខ្លួនបុគ្គលអ្នកមានសេចក្ដីសុខផងដែរ បើជាអ្នករងទុក្ខលំបាកវេទនាវិញនោះ ប្រាកដជាមិនអាចធ្វើបុណ្យឱ្យកើតឡើងបានឡើយ ។

អបញ្ញស្សកុតោនិព្វានំៈ ការបណ្ដុះព្រះនិព្វានតែងកើតមានអាស្រ័យទៅលើបុណ្យកុសល ដែលខ្លួនបានធ្វើទុកមក គឺនិព្វានកើតមានដោយសារនិស្ស័យនៃបុណ្យកុសល បើគ្មានបុណ្យកុសល តើនិព្វាននឹងកើតឡើងដល់ខ្លួនដូចម្ដេចបាន?

# សប្បុរិសធម៌ ៧ ប្រការ

ធម៌របស់សប្បុរស ហៅថាធម៌សប្បុរិសធម៌មាន ៧យ៉ាងគឺ:

១- ធម្មញ្ញុតា: ភាពជាអ្នកស្គាល់ហេតុ ដូចជាស្គាល់ថាធ្វើបុណ្យជាហេតុនាំឱ្យបានសុខ ធ្វើបាបជាហេតុនាំឱ្យមានទុក្ខជាដើម ។

២- អត្ថញ្ញុតា: ភាពជាអ្នកស្គាល់ផល ដូចស្គាល់ថាសេចក្ដីសុខជាផលដែលកើតមកពីការធ្វើល្អ សេចក្ដីទុក្ខជាផលកើតមកពីការធ្វើអាក្រក់ជាដើម ។

៣- អត្តញ្ញុតា: ភាពជាអ្នកស្គាល់ខ្លួន ដូចស្គាល់ថាអាត្មាអញនេះ មានជាតិត្រកូល យសសក្តិ សម្បត្តិបរិវារ សេចក្ដីចេះដឹង គុណធម៌ដែលមានក្នុងខ្លួនតែប៉ុណ្ណោះ ហើយប្រព្រឹត្តសមគួរ ដល់ឋានៈរបស់ខ្លួន ។

៤- មត្តញ្ញុតា: ភាពជាអ្នកស្គាល់ប្រមាណ គឺស្គាល់ប្រមាណក្នុងការស្វែងរកទ្រព្យសម្បត្តិ ចិញ្ចឹមជីវិតដោយផ្លូវប្រពៃ ព្រមទាំងស្គាល់ប្រមាណក្នុងការបរិភោគ ។

៥- កាលញ្ញុតា: ភាពជាអ្នកស្គាល់ពេលវេលា គឺស្គាល់វេលាណាដែលគួរសិក្សាចំណេះវិជ្ជា និងប្រកបកិច្ចការរកទទួលទាន វេលាណាដែលត្រូវអាក់ខានដូចជាថ្ងៃ ឧបោសថសីល ឬថ្ងៃបុណ្យជាដើម ។

៦- បរិសញ្ញុតា: ភាពជាអ្នកស្គាល់ប្រជុំជន និងកិរិយាដែលត្រូវប្រព្រឹត្តក្នុងទីប្រជុំជននោះៗ ថាពួកនេះកាលទៅរកត្រូវ ធ្វើកិរិយាយ៉ាងនេះៗ ត្រូវនិយាយនេះ ។

៧- បុគ្គលបរោបរញ្ញុតា: ភាពជាអ្នកស្គាល់បុគ្គលថា អ្នកនេះជាមនុស្សល្អគួររាប់រក អ្នកនេះជាបុគ្គលមិនល្អមិនគួររាប់រកប៉ុណ្ណោះជាដើម ។

**ចប់ដោយសង្ខេប**